# រៀមច្បង
# សហគមន៍ឥន្ទធនូកម្ពុជា

## ដំណើររឿងនៃការកសាងវិថីសម្រាប់
## សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា



សហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)

មិថុនា ២០២៤

# រៀមច្បង
# សហគមន៍ឥន្ទធនូកម្ពុជា

## ដំណើររឿងនៃការកសាងវិថីសម្រាប់
## សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា

សហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)

មិថុនា ២០២៤

# មាតិកា


០១ ខលឡេត អូរីហ្គាន់ ............................... ១
០២ ណយ ស៊ីថា ........................................ ៩
០៣ ផេង សាញ់ ........................................ ១៧
០៤ ម៉ី ចាន់ថន .......................................... ២៣
០៥ ឌុល ថុល ............................................ ២៩
០៦ ហ៊ន ឈឿន ........................................ ៣៧
០៧ ផាង សាមីន ........................................ ៤៣
០៨ សំ សែន ............................................ ៤៩
០៩ សុត យន់ ............................................ ៥៧
១០ សែម អៀង .......................................... ៦៣
១១ ផាន់ សារី .......................................... ៦៩
១២ ស៊ន នឿន .......................................... ៧៥



# ខលទៀត អ្វីហ្គាន់

អនុប្រធានក្រុមប្រឹក្សាភិបាល / សហស្ថាបនិក
អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)

# បារម្ភកថា

ជាការចាប់ផ្តើមនៃកម្រងសាច់រឿងរបស់សមាជិកដែលជារៀមច្បងនៃអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) ពួកយើងសូមរំលឹកសាច់រឿង និងអនុស្សាវរីយ៍ល្អៗជាមួយ លោកស្រី ខលទ្បេត អូរីហ្គាន់ ( **Collette O'Regan** ) ដែលជាអនុប្រធានក្រុមប្រឹក្សាភិបាល និងជាសហស្ថាបនិកមួយរូបរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)។

## សាច់រឿងនៃកម្មវិធីសប្តាហ៍មោទនភាព ឆ្នាំ២០០៩

ក្នុងឆ្នាំ២០០៩ អ្នកធ្វើការងារស្ម័គ្រចិត្តមួយក្រុមដែលមាន **Claire, Alan, Meg, and Collette O'Regan** បានជួប និងជជែកគ្នាលេង ក្នុងនាមជាមិត្តភក្តិដូចធម្មតា។ ពេលមួយពួកគាត់ស្រាប់តែមាន សំណួរផុសឡើងថាតើនៅក្នុងប្រទេសកម្ពុជាមានស្រ្តីស្រឡាញ់ស្រ្តីដែរឬយ៉ាងណា? នៅពេលនោះវត្តមាននៃសហគមន៍បុរសស្រឡាញ់បុរស និងបុរសប្តូរយេនឌ័រជាស្រ្តីក៏មានការបង្ហាញមុខច្រើនតាមរយៈកម្មវិធីសុខភាពសាធារណៈនៃការការពារ និងលុបបំបាត់ការឆ្លងមេរោគ និងជំងឺអេដស៍ ដែលវត្តមានរបស់ស្រ្តីស្រឡាញ់ស្រ្តី មិនសូវត្រូវបានកត់សម្គាល់ឃើញនោះទេ។ មិត្តភក្តិក្នុងស្ថាប័នអង្គការដែល **Collette** កំពុងតែបំពេញការងារស្ម័គ្រចិត្តនោះបានប្រាប់ព័ត៍មានពីអង្គការមួយដែលធ្វើការអនុវត្តគម្រោង ដោះស្រាយបញ្ហាមេរោគ និងជម្ងឺអេដស៍។ អ្នកតំណាងសហគមន៍មួយចំនួននៃអង្គការបណ្តាញការងារស្រ្តីរួបរួមគ្នា **(WNU)** បានមកចូលរួមប្រជុំពិភាក្សា មានដូចជា៖ ណយ ស៊ីថា ផេង សាញ់ និង ចក់ សោភ័ណ្ឌ ដែលបានកំណត់ខ្លួនថាជាអ្នកប្តូរយេនឌ័រពីស្រ្តីទៅជាបុរស ដោយកាលនោះពួកគាត់បានដឹងត្រឹមថាខ្លួនជាស្រីតែចរិត ឬចិត្តប្រុស និង លី ពិសី ដែលបានកំណត់ខ្លួនថាជាស្រ្តីស្រឡាញ់ស្រ្តី មកពីអង្គការកម្មវិធីស្រ្តី ដើម្បីការផ្លាស់ប្តូរ **(WAC)** ដែលជាអង្គការគាំទ្រដល់ **WNU** ហើយឈ្មោះរបស់ពួកគាត់ក៏នឹងត្រូវបានលើកឡើងនៅក្នុងកម្រងសាច់រឿងនេះផងដែរ។

ចាប់ពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០០៩ ពួកយើងក៏បន្តដំណើរការជជែកពិភាក្សាជាបន្តបន្ទាប់ដោយចាប់ផ្តើមពីការស្គាល់គ្នាបែបសាមញ្ញៗ និងបន្តិចម្តងៗចែករំលែកហើយរៀនសូត្រពីបទពិសោធន៍នៃការប្រារព្ធរៀបចំកម្មវិធីសប្តាហ៍មោទនភាពនៅប្រទេសនានាដែលជា

ឱកាសនៃការមកជួបជុំ និងរាប់អានគ្នាជាមិត្តភក្តិ។ លុះដល់ថ្ងៃទី១៧ ខែឧសភា ដែលជាការឈប់សម្រាកនាឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទសម្តេច នរោត្តម សីហមុនី កម្មវិធីសប្តាហ៍មោទនភាពក៏បានរៀបចំលេចចេញជារូបរាងឡើង ហើយបានប្រារព្ធពេញមួយសប្តាហ៍ ដោយមានការចូលរួមពីស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស និងអ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី ។




ផ្ទាំងរូបភាព (Poster) នៃទិវាសប្តាហ៍មោទនភាពអ្នកស្រឡាញ់ភេទដូចគ្នាឆ្នាំ២០០៩

## ការកើតចេញការកំណត់តួនាទី និងការងាររបស់រ៉ាក់ ( អាណត្តិ )

កម្មវិធីនេះបានជំរុញទឹកចិត្តរបស់ស៊ីថា និងសាញ់ជាខ្លាំង ដែលពួកគាត់បានមកនិយាយជាមួយ Collette ដោយរីករាយ និងសាកសួរពីអ្វីដែលពួកយើងអាចធ្វើបាន ក្រោយពីការជួបជុំគ្នានាពេលនោះ។ ឆ្លើយតបនឹងសំណួរនេះ Collette ក៏បានលើកសំណួរមួយឡើងថា « តើពួកយើងជាអ្នកណា? » ជាសំណួរដែលជំរុញឱ្យមានដំណើរការ ពិគ្រោះយោបល់ក្នុងទម្រង់ជាសិក្ខាសាលាប៉ាន់ប្រមាណពីតម្រូវការនៃសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា។ សិក្ខាសាលាពិគ្រោះយោបល់នោះ បានធ្វើឡើងដើម្បីស្វែងយល់ពី

បញ្ហាអាទិភាពដែលបុគ្គលនៃអត្តសញ្ញាណនីមួយៗនៅក្នុងសហគមន៍ ទាំងបុរសស្រឡាញ់បុរស អ្នកប្តូរយេនឌ័រជាស្ត្រី អ្នកប្តូរយេនឌ័រជាបុរស និងស្ត្រីស្រឡាញ់ស្ត្រីកំពុងជួបប្រទះ។ ការពិភាក្សាក៏បានបើកកកាយ និងស្វែងយល់ពីអត្តសញ្ញាណនៃភាពជា « អ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស » និង « ស្ត្រីស្រឡាញ់ស្ត្រី »។ ពេលនោះ អ្នកខ្លះក៏បានចាប់ផ្តើមស្វែងយល់ ផ្ទះពី លក្ខណៈសម្បត្តិ ដែលស្របនឹងអត្តសញ្ញាណភេទ និងយេនឌ័ររបស់ខ្លួន ហើយសួរសំណួរថា « តើអត្តសញ្ញាណនេះពិតជាអាចមានមែន ឬ? » ដែលនាំទៅរកការស្គាល់ពី « ខ្លួនឯង »។

ក្រោយពីនោះ អ្វីដែលជាលទ្ធផលនៃការពិគ្រោះយោបល់នោះ គឺការកើតចេញជាតួនាទី និងការងារ(អាណត្តិ)របស់រ៉ក់ ក្នុងការដោះស្រាយបញ្ហានៃការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា ដែលឯកសារនោះមានឈ្មោះថា៖ « យើងជាអ្នកណា »។ ឯកសារគោលនេះ បានផ្តល់នូវភាពច្បាស់លាស់ និងជាមូលដ្ឋានរឹងមាំមួយ។ បើទោះជារ៉ក់ ទទួលបានការចាប់អារម្មណ៍ពីម្ចាស់ជំនួយជាច្រើននៅក្នុងពេលនោះក៏ដោយ រ៉ក់ក៏បានឈានម្តងមួយជំហានៗ ដោយមានគោលជំហរច្បាស់លាស់ ហើយមិនបង្កើតកំហុសនៃការកសាងស្ថាប័ន ដោយឈរលើថវិកា ឬមូលនិធិ។ ផ្ទុយទៅវិញ រ៉ក់ផ្តោតយ៉ាងសំខាន់លើដំណើរ នៃការកសាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដ៏រឹងមាំ។ អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) មានអត្ថន័យផ្សារភ្ជាប់រវាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅលើសកលលោក ដែលតំណាងដោយមានពណ៌ឥន្ទធនូជាគោល។

## ព្រឹត្តិការណ៍អនុស្សាវរីយ៍

អំឡុងពេលកម្មវិធីសប្តាហ៍មោទនភាពអ្នកស្រឡាញ់ភេទដូចគ្នាតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ ២០១២ ដែលបានប្រារព្ធនៅភោជនីយដ្ឋានបៃតង រ៉ក់បានទទួលស្វាគមន៍មិត្តភក្តិ ដែលមកពីស្ទើរគ្រប់ប្រទេសនៃសមាជិកតំបន់អាស៊ីអាគ្នេយ៍ ឬអាស៊ាន លើកលែងតែប្រទេសប្រ៊ុយណេ។ នៅក្នុងព្រឹត្តិការណ៍នោះ ក៏មានកម្មវិធីចែករំលែកមួយ ដែលមានម្តាយដែលមានកូនប្រុសជាអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ មកពីប្រទេសវៀតណាមបានរៀបរាប់ប្រាប់អំពីរឿងរ៉ាវនៃការផ្សះផ្សារបស់ពួកគាត់ទាំងពីរនាក់ គឺនៅពេលដែលកូនប្រុសម្នាក់នោះបានបង្ហាញនូវការឈឺចាប់របស់ខ្លួនទៅកាន់ម្តាយ ហើយម្តាយមិនអាចទទួលយកក្តីស្រឡាញ់របស់គាត់បាន។

មិត្តភក្តិដែលជាសមាជិកសហគមន៍របស់យើង បានយំខ្សឹកខ្សួលដោយការរំជួលចិត្ត ដែលម្តាយម្នាក់ នោះអាចទទួលយកកូនរបស់ខ្លួនបានដោយពិតប្រាកដ។ ពួកគាត់ក៏មានក្តីសង្ឃឹមថា ឪពុកម្តាយរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា អាចទទួលយកកូនៗបានតាមរយៈការងាររបស់រ៉ក់។




រូបថតក្នុងឱកាសទិវាសប្តាហ៍មោទនភាព
អ្នក្រស់ឡាញ់ៗភទដូចគ្នាឆ្នាំ២០១២




រូបថតក្នុងឱកាសទិវាសប្តាហ៍មោទនភាព
អ្នកស្រឡាញ់ភេទដូចគ្នាឆ្នាំ២០១៤

ព្រឹត្តិការណ៍នេះ ក៏បានអនុញ្ញាតឱ្យមិត្តភក្តិដែលជាអ្នកស្រឡាញ់ភេទដូចគ្នា មកពីប្រទេសផ្សេងៗ ចំណាយពេលជាមួយគ្នានៅកន្លែងតែមួយ។ ដូចនេះការរៀនឆ្លុះបញ្ចាំងស៊ីជម្រៅ ក៏បានកើតឡើងផងដែរ ដោយយើងបានរៀនពីមិត្តភក្តិ ដែលមកពីប្រទេសសិង្ហបុរី ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី គឺថា៖ ទី១ ប្រទេសកម្ពុជា គឺជាប្រទេសដែលមានសុវត្ថិភាពគួរសមសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ ទី២ អ្វីដែលយើងមិនទាន់អាចធ្វើបាន នៅទីតាំងមួយ ឬប្រទេសមួយនៅឡើយ តែយើងនៅតែអាចធ្វើបាននៅទីតាំង ឬប្រទេសដទៃទៀត តួយ៉ាងការចាក់បញ្ចាំងភាពយន្ត និងការតាំងពិព័រណ៍ ដែលជម្ទះទៅនឹងគំនិតស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នាអាចប្រព្រឹត្តិទៅបាននៅរាជធានីភ្នំពេញ។ ពួកគេក៏អាចផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានដែលជាវិធីសាស្រ្ត ក្នុងការបង្ហាញទៅដល់ប្រទេសរបស់ខ្លួនផងដែរ។ មិត្តភក្តិខ្មែរអាចរៀនសូត្រ

ពីបរិបទប្រទេសផ្សេងៗ ហើយផ្លាស់ប្តូរការយល់ឃើញ និងដឹងថា ទោះនៅទីណាក៏ដោយ ក៏សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាត្រូវតែសកម្មជានិច្ច ហើយធ្វើកិច្ចការដែលគេត្រូវធ្វើនោះ គេអាចមើលឃើញឱកាស និងប្រើប្រាស់លទ្ធភាពរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាដែលគេពើបប្រទះ ក្នុងបរិបទពួកគេរស់នៅ។ ព្រឹត្តការណ៍ដែលគួរឱ្យចងចាំមួយទៀតនោះគឺ សន្និបាតសមាជិកសមាគមអ្នកស្រឡាញ់ភេទដូចគ្នា នៅក្នុងថ្នាក់តំបន់អាស៊ី **(ILGA Asia Conference)** នៅខែធ្នូ ឆ្នាំ២០១៧ ដែលពួកយើងអាចបង្ហាញថាកម្ពុជាអាចធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំព្រឹត្តិការណ៍ដ៏ធំម្តងទៀត ដោយបានទទួលស្វាគមន៍មិត្តភក្តិជាសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកគាំទ្រចំនួន២៨១នាក់មកពី ៣៩ប្រទេស ដែលភាគច្រើនមកពីតំបន់អាស៊ី[1] ។



សប្តាហ៍មោទនភាព អ្នកស្រឡាញ់ភេទដូចគ្នា ឆ្នាំ២០១៤ នៅស្ថានទូតស៊ុយអែតប្រចាំប្រទេសកម្ពុជា

## សារសម្រាប់អ្នកជំនាន់ក្រោយ

ក្នុងរយៈពេល១៨ឆ្នាំកន្លងមក រ៉ក់បានលូតលាស់ដោយរឹងមាំ និងបានសម្រេចលទ្ធផលជាច្រើន ដោយមានការចូលរួមចំណែកពីសមាជិកសហគមន៍របស់ខ្លួន ជាពិសេសសមាជិកសកម្មវ័យចំណាស់ ដែលដើរតួនាទីដ៏សំខាន់គួរឱ្យគោរព និងស្ញប់ស្ញែង។ ពួកគាត់បានឆ្លងកាត់នូវពេលវេលា ដែលលំបាកជាច្រើននៅក្នុងប្រទេសកម្ពុជា រាប់ទាំងរក្សានូវភាពពិតនៃនិន្នាការ

---

[1] របាយការណ៍សន្និបាត ILGA Asia Conference 2017 ។
មាននៅ៖ https://www.ilgaasia.org/publications/2018/4/21/conference-report-7th-ilga-asia-conference-foreword-from-ilga-asia-executive-board

ភេទ និងអត្តសញ្ញាណយេនឌ័ររបស់ខ្លួន។ ដូចនេះហើយ គ្មាននរណាម្នាក់អាចនិយាយថា អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាមិនរឹងមាំ ឬសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាបានទទួលឥទ្ធិពលពីបរទេសនោះទេ! ពួកគាត់ គឺជាភស្តុតាងពិតប្រាកដនៃភាពធន់ និងភាពរឹងមាំ ហើយខ្ញុំសង្ឃឹមថាអ្នកជំនាន់ក្រោយ ក៏មើលឃើញគុណតម្លៃនេះ។ សារមួយ ដែលសំខាន់ទៅកាន់អ្នកជំនាន់ក្រោយនោះ គឺថាការប្រែប្រួល រមែងកើតឡើង និងបន្តកើតឡើង ប្រៀបដូចទៅនឹងទូកដែលនៅលើផ្ទៃសមុទ្រ ដែលពេលខ្លះក៏ត្រូវជួបនឹងព្យុះភ្លៀងដែរ។ តែអ្វីដែលអាចជួយពួកយើងក្នុងនាមជារ៉ក់ ឱ្យអាចទប់ទល់នឹងព្យុះភ្លៀង ហើយធ្វើការសម្រេចចិត្តបានល្អ គឺការឆ្លុះបញ្ចាំង រៀនសូត្រ និងគោរពនូវគុណតម្លៃរបស់រ៉ក់។



# ណយ ស៊ីថា

អ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស រស់នៅសង្កាត់បឹងទំពុនទី២
ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លោក ណយ ស៊ីថា ឬ ប៉ា ស៊ីថា កើតនៅក្នុងឆ្នាំ១៩៥១ មានស្រុកកំណើតក្នុងស្រុកបាទី ខេត្តតាកែវ និងបច្ចុប្បន្នកំពុងរស់នៅរាជធានីភ្នំពេញ។ លោកកំណត់ខ្លួនជាបុរស ឬសព្វថ្ងៃយើងហៅថាអ្នកប្តូរអត្តសញ្ញាណយេនឌ័រជាបុរស។ គាត់ដឹងថាខ្លួនជាក្មេងប្រុសតាំងពីអាយុ៨ឆ្នាំមកម្ល៉េះ តែលុះដល់វ័យជំទង់ ចន្លោះអាយុ១៣ ទៅ១៦ឆ្នាំ ទើបលោកបានកាត់សក់ និងតុបតែងខ្លួន ជាខ្លួនឯងពេញលេញ។ ពេលលេងល្បែងរៀបការ លោកតែងតែដើរតួជាប្តី ព្រោះជាតួនាទី ដែលគាត់យល់ថាត្រូវនឹងខ្លួនឯង។ ប៉ុន្តែគាត់ក៏មិនបានបង្ហាញពីអត្តសញ្ញាណខ្លួនដែរ ទាល់តែប្រាកដចិត្តពេលពេញវ័យ ចេះស្រឡាញ់ស្រ្តីម្នាក់។ អត្តចរិត និងការបង្ហាញខ្លួនរបស់គាត់មិនសូវជាទទួលប្រតិកម្មអវិជ្ជមានពីគ្រួសារទេ ដែលឪពុករបស់គាត់តែងតែហៅគាត់ «អាពៅ» ឬ «អាប្រុស» ជាដើម។ រីឯអ្នកនៅក្នុងភូមិស្រុករបស់គាត់ក៏មិនប្រកាន់ ឬមានពាក្យសម្តីមិនសមរម្យមកលើគាត់ និងអ្នកស្រឡាញ់ភេទដូចគ្នាជាទូទៅប៉ុន្មាននោះដែរ។ គាត់លើកឡើងនូវឧទាហរណ៍ថា នៅក្នុងភូមិក៏ធ្លាប់មានដៃគូ ដែលជាស្រ្តីប្តូរយេនឌ័រជាបុរសអាចរៀបការជាមួយអ្នកប្តូរយេនឌ័រជាស្ត្រី ហើយរស់នៅជាមួយគ្នាជាធម្មតា។ ប៉ាស៊ីថាចូលចិត្ត និងស្រឡាញ់សិល្បៈ ដែលលោកបានចូលរួមសម្តែងល្ខោនបុរាណតាំងពីកុមារភាព។ គាត់បានបន្តអាជីពនេះដោយមកធ្វើការនៅភ្នំពេញ ជាអ្នកចម្រៀងទាំងផ្នែកបុរាណ និងសម័យនៅវិទ្យុជាតិកម្ពុជា។ បន្ទាប់មក ប៉ាក៏បានបម្រើការជាមន្រ្តីមួយរូបរបស់ស្ថានីយ៍វិទ្យុជាតិនៃក្រសួងព័ត៌មាន តែសព្វថ្ងៃប៉ាបានចូលនិវត្តន៍ហើយ និងនៅផ្ទះមើលថៃចៅៗជាមួយនឹងភរិយា។

## ការជួបជុំគ្នា និងកសាងទៅជាសហគមន៍មួយ

ក្នុងឆ្នាំ១៩៦៨ គាត់បានមករស់នៅ និងធ្វើការនៅភ្នំពេញ ដែលបណ្តាលឱ្យគាត់បានស្គាល់ និងជួបជុំមិត្តភក្តិភាគច្រើន គឺជាអ្នកប្តូរយេនឌ័រជាបុរស ក៏ដូចដៃគូរបស់ពួកគាត់ផងដែរ។ គាត់និទានថា៖ « *យើងជួបគ្នាម្តងៗ ប្រមាណ៣០ដៃគូ ពេលខ្លះយើងដើរលេង និងមកស្នាក់នៅជុំគ្នានៅផ្ទះរបស់ខ្ញុំ។ មានឪពុកម្តាយខ្លះ ដែលមិនទទួលយកកូនដែលស្រឡាញ់ភេទដូចគ្នា បានមករកកូនដល់ផ្ទះខ្ញុំ ហើយខ្ញុំក៏ជួយនិយាយសម្រួលផង បញ្ចុះបញ្ចូលផងរហូតដល់ពួកគាត់អាចស្រប និងទទួលយកកូនបាន។* »




ប៉ាស៊ីថា និងប្រពន្ធ ( ម៉ែរឿន ) ក្នុងឱកាសទិវាសប្តាហ៍មោទនភាពអ្នកស្រឡាញ់ភេទដូចគ្នាឆ្នាំ២០១២

ចូលមកដល់ឆ្នាំ២០០១ ប៉ាស៊ីថាបានស្គាល់មិត្តភក្តិជាអ្នកប្តូរយេនឌ័រជាស្ត្រីម្នាក់ទៀតធ្វើការនៅស្ថាប័នមួយ ឈ្មោះថាអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា និងសាកសួរពីការជួយចងក្រងអ្នកដែលមានអត្តសញ្ញាណដូចគាត់ ឬជាអ្នកដែលស្រឡាញ់ភេទដូចគ្នា « ស្ត្រីតាំងខ្លួនជាបុរស » ដោយកាលនោះមិនទាន់ប្រើពាក្យថា ជាអ្នកប្តូរអត្តសញ្ញាណយេនឌ័រនៅឡើយទេ។ គាត់ក៏បានរៀនសូត្រពីសារៈសំខាន់នៃការងារចងក្រង និងចូលរួមជួយចងបណ្តាញ ជនបង្គោល និងមានក្រុមតាមតំបន់គោលដៅ ដើម្បីគាំទ្រគ្នា និងការពារពីភាពងាយរងគ្រោះ ជាពិសេសគឺការរើសអើង និងអំពើហិង្សា។ លុះដល់ឆ្នាំ២០០៩ ប៉ាស៊ីថាបានជួបជាមួយសហស្ថាបនិក

នៃអង្គការសហគមន៍ឥន្ទធនូកម្ពុជា ដទៃទៀត។ ពួកគាត់បានជជែកពិភាក្សាអំពីគំនិតផ្តួចផ្តើមនៃការកសាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាឡើង ដែលផ្តោតលើស្ថានភាពរស់នៅ បទពិសោធន៍ជីវិត តម្រូវការ និងគោលបំណង។ គាត់ និងមិត្តពីររូបទៀត គឺលោក ផេង សាញ់ និងលោកចក់ សោភ័ណ្ឌ ដែលជាអ្នកប្តូរយេនឌ័រពីស្រ្តីទៅបុរសបានចាប់ផ្តើមធ្វើការងារស្ម័គ្រចិត្ត ផ្នែកចងក្រងសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដែលមានទាំងអ្នកប្តូរយេនឌ័រជាស្រ្តី អ្នកប្តូរយេនឌ័រជាបុរស និងដៃគូដែលកំណត់ខ្លួនជាស្រ្តី។ គាត់បានចងក្រងអ្នកដែលនៅក្នុងបណ្តាញរបស់គាត់ស្រាប់ ក៏ដូចជាអ្នកមិនធ្លាប់ស្គាល់នៅតាមបណ្តាខេត្តនានា។ អ្នកទាំងបីតែងជិះម៉ូតូជាមួយគ្នាទៅជាយក្រុង និងខេត្តជិតៗរាជធានីភ្នំពេញ ហើយហូបបាយដែលបានវេចពីផ្ទះជុំគ្នា ដែលជាអនុស្សាវរីយ៍ដ៏ស្និតស្នាញ និងរីករាយមិនអាចបំភ្លេចបាន។ ប៉ុន្តែគួរឱ្យសោកស្តាយយ៉ាងធំធេង ក្នុងឆ្នាំ២០១១ លោក ចក់ សោភ័ណ្ឌ បានលាចាកលោកដោយសាររោគាពាធ បន្សល់ទុកនូវមិត្តភក្តិទាំងពីររូប ឱ្យនៅធ្វើកិច្ចការងារកសាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបន្តទៅទៀត។




រូបថតរបស់ប៉ាស៊ីថា ប៉ាសាញ់ និង បងសោភ័ណ្ឌ ឆ្នាំ២០១០

ការដើរស្វែងរក និងស្គាល់អ្នកស្រឡាញ់ភេទដូចគ្នា ក៏ចេះតែបន្តវិវត្តទៅជាការផ្តួចផ្តើមគំនិតចងជាជនបង្គោល ឬតំណាងប្រចាំខេត្ត ហើយដើរឆ្លងពីខេត្តមួយទៅកាន់ខេត្តមួយទៀត ដើម្បីតភ្ជាប់ជាបណ្តាញសហគមន៍ និងចងមិត្តភាព។ អ្នកដែលបានចងក្រងរួចហើយនៅក្នុងខេត្ត

មួយក៏ត្រូវបានណែនាំឱ្យស្គាល់អ្នកផ្សេងទៀត ដែលជាមិត្ត ឬទៅជួយស្វែងរកអ្នកមិនទាន់ស្គាល់ក្នុងខេត្តនោះផងដែរ។ ក្នុងតំបន់ខ្លះ ប៉ាស៊ីថាក៏ចូលទៅរកពឹងពាក់មេឃុំ សូមឱ្យជួយណែនាំប្រាប់ពីភូមិ ដែលមានសមាជិកសហគមន៍ជាអ្នកស្រឡាញ់ភេទដូចគ្នា ដែលគាត់អាចទៅស្វែងរក និងទំនាក់ទំនងបាន។

ជាលទ្ធផល វ៉ក់ក៏មានសមាជិកជាអ្នកស្រឡាញ់ភេទដូចគ្នាកាន់តែច្រើនឡើង និងបណ្ដាញអាជ្ញាធរមូលដ្ឋានមួយចំនួន ដែលមានសក្ដានុពលគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នាក្នុងចំណោម ២៤ខេត្ត និងរាជធានីភ្នំពេញ។ បន្ថែមទៅលើនោះ ប៉ាបានប្រើប្រាស់ជំនាញ និងទេពកោសល្យរបស់ខ្លួនដូចជាការតាក់តែង និងប្រើប្រាស់សិល្បៈចម្រៀង ក្នុងការបង្ហាញសាច់រឿង និងបទពិសោធន៍ពិតដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះ ជាសារផ្សព្វផ្សាយ និងកាត់បន្ថយការរើសអើងទៅលើសហគមន៍ខ្លួន។

## ការដើរដង្ហែរជាសាធារណៈដោយមានមោទនភាពនិងទំនុកចិត្ត




ក្បួនដង្ហែរកង់បី របស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្នុងរាជធានីភ្នំពេញឆ្នាំ២០១៦

ប៉ាស៊ីថារំលឹកពីសកម្មភាព នៃកម្មវិធីសប្ដាហ៍មោទនភាព និងកម្មវិធីទិវាសិទ្ធិមនុស្សអន្តរជាតិ ដែលអង្គការសហគមន៍ឥន្ទធនូកម្ពុជាបានប្រារព្ធឡើងថា៖ « *សាកស្រមៃមើលទៅ ថាតើខ្ញុំមានមោទនភាព និងព្រឺសម្បុរប៉ុណ្ណា នៅពេលដែលមនុស្សធ្លាប់តែដើរម្នាក់ឯង អៀនៗ តែដល់ពេលមួយនោះ យើងមានគ្នាច្រើននាក់ដង្ហែររ៉ឺម៉កកង់បី និងដើរជាសាធារណៈដោយ ពើងទ្រូង ពាក់អាវ និងចងទង់ឥន្ទធនូដែលមានពាក្យថាមោទនភាពអ្នកស្រឡាញ់ភេទដូចគ្នា ដែលបង្ហាញថាពួកយើងជាអ្នកណាទៅកាន់មនុស្សជាច្រើន ដែលកំពុងសម្លឹងមើលមកពួកយើង។ ពួកយើងទាំងអស់គ្នា ដើររើសសំរាមដែលបង្ហាញទៅសាធារណជនថា ទោះជាយើងជាអ្នកស្រឡាញ់ភេទដូចគ្នា តែយើងចេះចូលរួមធ្វើកិច្ចការការងារសង្គម និងសេវាសាធារណៈនេះដែរ។* »




ប៉ាស៊ីថា និងប៉ាសាញ់ ក្នុងឱកាសសប្ដាហ៍មោទនភាពឆ្នាំ២០១៦

ចាប់ពីឆ្នាំ២០១៣រហូតដល់ឆ្នាំ២០១៦ ប៉ាស៊ីថាបានក្លាយជាបុគ្គលិកអង្គការសហគមន៍ឥន្ទធនូកម្ពុជា ហើយបន្តកិច្ចការងារចងក្រងសមាជិកអ្នកស្រឡាញ់ភេទដូចគ្នា។ សព្វថ្ងៃលោកនៅតែបន្តចូលរួមជាមួយអង្គការសហគមន៍ឥន្ទធនូកម្ពុជា ក្នុងសកម្មភាពខ្លះៗដូចជាកម្មវិធីតស៊ូមតិថ្នាក់ជាតិតាមរយៈកិច្ចសន្ទនាជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជាជាដើម។ តាមរយៈការចូលរួមនេះ លោកបានលើកឡើងថា៖ « ប៉ាពិតជាសប្បាយចិត្ត និងមានមោទនភាពណាស់ នៅពេលដែលបានមើលឃើញសមាជិក ដែលខ្លួនធ្លាប់បានចងក្រង

មានភាពសកម្ម មានសេចក្តីក្លាហានកាន់មេក្រូ និងលើកជាមតិ នៅចំពោះមុខមន្រ្តីជាន់ខ្ពស់មកពីក្រសួងស្ថាប័នថ្នាក់ជាតិ។ » លោកក៏ផ្ញើសារទៅកាន់សមាជិកជំនាន់ក្រោយដែរថា៖ « *រ៉ក់ គឺជាស្ថាប័នអ្នកស្រឡាញ់ភេទដូចគ្នាដ៏រឹងមាំរួចហើយ ដូចជាទូកដឹកនាំពួកយើងទាំងអស់គ្នា តែយើងជាសមាជិកម្នាក់ៗ ត្រូវតែមានសាមគ្គីភាព និងជួយគិតគូរ ពិចារណាជាមួយគ្នា ដែលអាចប្រៀបបាន ទៅនឹងចង្កឹះមួយបាច់កាច់មិនបាក់ឡើយ។* »

បើទោះជាមានវ័យចំណាស់ សុខភាពទន់ខ្សោយជាងមុន ហើយបានចូលនិវត្តន៍ពីការងារមន្រ្តីរាជការក៏ពិតមែន សមាជិកសហគមន៍រ៉ក់ និងប៉ាសុីថា មិនដែលនៅឆ្ងាយពីគ្នាឡើយ។ យើងតែងតែសួរសុខទុក្ខ ផ្ញើសេចក្តីនឹករលឹក និងអញ្ជើញចូលរួមនៅក្នុងកម្មវិធីផ្សេងៗរបស់រ៉ក់ ប្រកបដោយភាពស្និទ្ធស្នាល រីករាយ និងសកម្ម។ យើងអាចនិយាយបានថា អាយុគ្រាន់តែជាតួលេខ តែទឹកចិត្តស្រឡាញ់ គោរព និងគាំទ្រគ្នា គឺមិនសាបសូន្យឡើយ។ ការដឹងគុណ ការអរគុណ សេចក្តីគោរព ស្ញប់ស្ញែងចំពោះការតស៊ូ លះបង់ និងរួមចំណែកកសាងសហគមន៍រ៉ក់របស់ប៉ាសុីថាស្ថិតនៅក្នុងដួងចិត្តរបស់អ្នកជំនាន់ក្រោយជានិច្ច។




រូបថតជុំមិត្តភក្តិរួមសហគមន៍នៅក្នុងឱកាសកិច្ចសន្ទនាជាមួយតំណាងរដ្ឋាភិបាលក្នុងឆ្នាំ២០២៣



# ផេង សាញ់

ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស រស់នៅក្នុងក្រុងសួង
ខេត្តត្បូងឃ្មុំ

*« សួស្តីអូន អូនឯងស្រឡាញ់ភេទដូចគ្នាដែរអី ? »*
*« មានការអីបង ! ? »*
*« អី...ខ្ញុំជាអ្នកស្រឡាញ់ភេទដូចគ្នាដូចអូនឯងដែរនឹងហ្មាស! មានប្រពន្ធចាំនៅផ្ទះ ហ្នក...»*
*« បាទបង ខ្ញុំក៏មានប្រពន្ធចាំនៅផ្ទះដែរហ្នឹង ! »*

ខាងលើនេះជារបៀបដែលលោកផេង សាញ់ ចាប់ផ្តើមសន្ទនាជាមួយអ្នកដែលគាត់យល់ថាជាអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីទំនាក់ទំនងចងក្រងសមាជិក។ គាត់មានភេទកំណើតជាស្ត្រី បានកំណត់អត្តសញ្ញាណយេនឌ័រខ្លួនជាបុរស ដែលក្មេងៗក្នុងសហគមន៍ភាគច្រើនហៅគាត់ថា ប៉ាសាញ់។ កើតនៅឆ្នាំ១៩៥២ បើគិតត្រឹមឆ្នាំ២០២៣នេះ ប៉ាសាញ់មានអាយុ៧១ឆ្នាំហើយ។ កំណើតកើតជា ជាអ្នកស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល តែបច្ចុប្បន្ន ប៉ារស់នៅក្រុងសួង ខេត្តត្បូងឃ្មុំ ជាមួយប្រពន្ធរបស់គាត់។ ប៉ាជាសហស្ថាបនិកមួយរូបទៀត នៃអង្គការសហគមន៍ឥន្ទធនូកម្ពុជា ហើយបន្ទាប់មក បានទទួលតួនាទីជាបុគ្គលិកចងក្រងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមួយរូប ដែលចូលរួមជ្រោមជ្រែងការងារស្នូលរបស់រ៉ក់មួយនេះ ដើម្បីកសាងសេចក្តីក្លាហាន ជំរុញការចូលរួម និងពង្រឹងសាមគ្គីភាពឱ្យសហគមន៍មានភាពរឹងមាំ។

ប៉ាសាញ់អង្គុយតំណាលពីប្រវត្តិខ្លីៗប្រាប់កូនៗជំនាន់ក្រោយថា៖ *« កាលប៉ានៅក្មេង ប៉ាមិនបានគិតថាខ្លួនជាមនុស្សស្រីទេ។ រីឯការតុបតែងខ្លួន ក៏ដូច្នោះដែរ ដោយតែងប្រាប់គេឯងថា ប៉ាចង់កាត់សក់ឱ្យដូចយាយនោះ! »* និយាយបណ្តើរដៃចង្អុលទៅយាយៗ ដែលមានទម្រង់សក់ខ្លីៗបណ្តើរ។ ពេលទៅឃ្វាលគោម្តងៗ គាត់ស្លៀកតែខោក្រវ៉ាត់ក្រមានឹងចង្កេះ។
កាលនោះប៉ាសាញ់មានអាយុប្រហែល១០ឆ្នាំ ដោយសារឪពុកទៅធ្វើការ ហើយម្តាយទៅលក់ដូរបាត់ៗពីផ្ទះ ប៉ាមានពេលដើរលេងជាមួយមិត្តភក្តិ ទៅលេងប៊ូល វាយបាល់ និងបាញ់ឃ្លី។ ចំណែកការងារនៅផ្ទះរបស់ប៉ាវិញ គឺចិញ្ចឹមជ្រូកមាន់ និងដាំចេកពងមាន់នៅក្រោយផ្ទះ។ ប៉ាមានមាឌល្អិត ខ្លួនតូចក៏ពិតមែន ប៉ុន្តែការងារធ្ងន់ស្រាលមិនដែលខ្ជិលឡើយ លើកលីកព្រៃធំៗដើរប្រុយៗ។ ដោយអត្តចរិត និងការធ្វើការងារទាំងអស់នេះហើយទើបគេហៅគាត់ថា « អាស្តួយ » « អាស្ទាវ » ដែលជាពាក្យអ្នកស្រុកគាត់ហៅសម្គាល់មនុស្សប្រុសមានអត្តចរិតខិល ប៉ុន្តែគាត់សប្បាយចិត្តដែលគេហៅបែបនេះ ដែលនិយាយដល់ត្រង់នេះប៉ាក៏សើចកខឹក

ដោយអស់សំណើចខ្លួនឯង ទទួលស្គាល់ថាខ្លួនពិតជាមានចរិតខិលរបិលរប៉ូចមែន។ ចូលដល់វ័យ១៨ឆ្នាំ ក៏ជាពេលចាប់ផ្តើមមានស្នេហា និងបានលួចស្រឡាញ់នារីម្នាក់ដែលរៀនថ្នាក់ជាមួយគ្នា។ ជាកូនស្រីជំនាន់នោះ ប៉ាសាញ់ត្រូវបានឪពុកម្តាយហាមប្រាមយ៉ាងតឹងតែងបំផុត ទាំងការចេញក្រៅពេលយប់ព្រលប់ ទាំងការស្លៀកពាក់ សូម្បីតែខោថ្ងៃរប្រាំក៏ឪពុកមិនឱ្យស្លៀកដែរ។ ឱ្យតែដល់រដូវបុណ្យទានម្តងៗ ប៉ាសាញ់តែងយកសម្លៀកបំពាក់បងប្រុសមកស្លៀក និងលួចដើរលេងពេលយប់ ដើម្បីទៅជួបដៃគូស្នេហារបស់ខ្លួន។ ពេលខ្លះ ប៉ាក៏មានអារម្មណ៍ថាខ្លួនឯងហាក់ខុសគេ ខ្លួនជាមនុស្សស្រីតែមានអារម្មណ៍ និងក្តីស្រឡាញ់លើមនុស្សស្រីដូចគ្នា ហើយមានអត្តចរិតជាមនុស្សប្រុស ដែលនិយាយដល់ចំណុចនេះក៏ទឹកភ្នែករលីងរលោង។



រូបថត ប៉ាសាញ់ ក្នុងសិក្ខាសាលាជាមួយអាជ្ញាធរមូលដ្ឋាន នៅខេត្តកំពង់ឆ្នាំង ឆ្នាំ២០១៦

កាលពីជំនាន់ឆ្នាំ១៩៦២ ប៉ាធ្លាប់ឃើញមានបុរសស្រឡាញ់បុរស និងមានបុរសដែលមានអត្តចរិតទន់ភ្លន់ ទុកសក់វែង តុបតែងខ្លួន និងស្លៀកពាក់ដូចទៅនឹងនារី រស់នៅក្នុងភូមិជាមួយប៉ា ដែលភាគច្រើនមានការងារជាអ្នកត្បាញសូត្រ ហូល និងផាមួងជាដើម។ កាលនោះពុំទាន់មានពាក្យអ្នកស្រឡាញ់ភេទដូចគ្នានៅឡើយទេ ហើយជៀសមិនផុត ក៏មានអ្នកហៅ

ពួកគាត់ថា ជាមនុស្សប្រុសបែបបញ្ញើឌីដង។ រីឯការបំបែក និងបង្ខំរៀបការក៏កើតមានឡើងផងដែរ។ ជាការឆ្លុះបញ្ចាំងរបស់ប៉ាសាញ់៖ « *ជាអ្នកស្រឡាញ់ភេទដូចគ្នា ទោះដាក់ច្រវ៉ាក់ ឬបង្ខំឱ្យរៀបការជាមួយមនុស្សភេទផ្ទុយគ្នារហូតមានកូនទៀត ក៏នៅតែស្រឡាញ់ភេទដូចគ្នាដែរ ពិតជាមិនអាចប្ដូរបានទេ។* »

ក្នុងឆ្នាំ១៩៨៤ ដោយមានរបរលក់ដូរបន្លែប៉េងប៉ោះ និងដំឡូងនៅផ្សារមួយកន្លែង ប៉ាបានជួបនឹងប៉ាស៊ីថា ម៉ែរី និងប៉ាថននៅផ្សារនោះ។ ពេលឃើញគ្នាក៏ដឹងថាអ្នកទាំងបីនាក់មានអត្តសញ្ញាណដូចគ្នា ក៏រាប់គ្នាជាក្លើ ហើយប៉ាស៊ីថា ក៏នាំប៉ាសាញ់ទៅកាត់សក់ខ្លីដូចបុរសជាលើកដំបូងក្នុងជីវិត ហើយធ្វើឱ្យប៉ាសាញ់សប្បាយចិត្តណាស់ ដែលអាចកាត់សក់សមតាមបំណងរបស់ខ្លួន។ ក្រោយមកទៀត ប៉ាសាញ់ក៏បានចូលរួមជាមួយបណ្ដាញសហគមន៍មួយឈ្មោះថា អង្គការបណ្ដាញការងារស្ត្រីរួបរួមគ្នា ដែលធ្វើការលើក្រុមងាយរងគ្រោះ រួមមានអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ បន្ទាប់មកទៀតស្ថាប័ននោះ ក៏បានបង្កើតចេញជាស្ថាប័នមួយទៀតឈ្មោះថា អង្គការសេវាច្បាប់សម្រាប់សហគមន៍ ផ្ដល់សេវាផ្លូវច្បាប់ជួយការពារដល់អ្នកប្រកបរបរផ្លូវភេទ ដែលប៉ាសាញ់ត្រូវបានជ្រើសរើសជាបុគ្គលជួយគាំទ្រសហគមន៍តាមរយៈសេវាទូរស័ព្ទ ពិគ្រោះយោបល់ទាន់ហេតុការណ៍។ តាមរយៈបទពិសោធន៍ការងារទាំងនោះ ប៉ាបានមានទំនាក់ទំនង និងចូលរួមសកម្មភាពមួយចំនួនរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា ហើយបានប្រើប្រាស់ជំនាញ និងចំណេះដឹង នៃការចងក្រង និងទំនាក់ទំនងជាមួយសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។

ពេលនឹកដល់ការចូលរួមជាមួយរ៉ក់ ប៉ាសាញ់បានរំលឹកពីពេលវេលា ដែលបានជួបជាមួយនឹងខលឡេត ( Collette ) ដែលជាសហស្ថាបនិកមួយរូបទៀតរបស់រ៉ក់ ហើយកាលនោះជាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ធ្វើការស្ម័គ្រចិត្តនៅប្រទេសកម្ពុជា មិនទាន់បានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលនៅឡើយទេ។ ប៉ាភ្ញាក់ផ្អើល ដោយការស្គាល់ពីអត្តសញ្ញាណស្ត្រីស្រឡាញ់ស្ត្រីពី Collette ដែលពីមុនប៉ា និងអ្នកដទៃទៀត តែងយល់ថាមានតែស្ត្រីតាំងខ្លួនជាបុរសប៉ុណ្ណោះ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា! នេះជាបទពិសោធន៍ដ៏គួរឱ្យភ្ញាក់ផ្អើល បើកភ្នែក បើកត្រចៀកដំបូងមួយ ដែលធ្វើឱ្យគាត់មើលឃើញថា សហគមន៍ខ្លួននៅមានចំណេះដឹងទូលាយជាច្រើនទៀត អំពីអ្នកស្រឡាញ់ភេទដូចគ្នាដែលខ្លួន និងសហគមន៍ខ្លួនត្រូវស្វែងយល់

និងរៀនសូត្របន្ថែម។ គាត់ក៏បង្កើនចំណាប់អារម្មណ៍ចំពោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាច្រើនជាងមុន។

នាឱកាសកម្មវិធីសប្តាហ៍មោទនភាព ដែលរ៉ក់បានប្រារព្ធធ្វើឡើងជាលើកដំបូងក្នុងឆ្នាំ២០០៩ ប៉ាសាញ់គិតថាខ្លួនចង់ធ្វើអ្វីម៉្យាងសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត។ ផ្តើមចេញពីការចូលរួមធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលរបស់រ៉ក់មួយរូប។ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ ប៉ាក៏បានបន្តនៅជាមួយរ៉ក់ ដោយបានដាក់ពាក្យធ្វើជាបុគ្គលិកពេញម៉ោង ដែលមានតួនាទីជាអ្នកចងក្រងសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ នៅតាមបណ្តាខេត្តនានា ជាមួយក្រុមការងារចងក្រងរបស់រ៉ក់ផ្សេងទៀត។ ប៉ាបានលើកឡើងថា៖ *« ប៉ាចាត់ទុករ៉ក់ដូចជាបេះដូងរបស់ប៉ា ដែលបេះដូងនេះជាបេះដូងរបស់អ្នកស្រឡាញ់ភេទដូចគ្នា! »*




រូបថត ចុះកសាងទំនាក់ទំនង ជាមួយអាជ្ញាធរមូលដ្ឋាន ឆ្នាំ២០១៦




រូបថត ក្រោយសិក្ខាសាលាជាមួយ អាជ្ញាធរមូលដ្ឋាន នៅខេត្តកំពង់ឆ្នាំង ឆ្នាំ២០១៦

ពេលចុះចងក្រងនៅតាមមូលដ្ឋានម្តងៗ ភ្នែកខំមើលសម្លឹងរកគ្នា អ្នកដែលមានអត្តសញ្ញាណដូចខ្លួន និងក្រុមស្រីស្រស់ ឬអ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រី។ គាត់ចាប់សម្គាល់ដំបូងគឺការតុបតែងខ្លួន ឬកាត់សក់ខ្លី ទោះម្នាក់នោះមិនកាត់សក់ក៏អាចមើលដឹងតាមរយៈអាកប្បកិរិយាដែរ។ នៅពេលសួរនាំរួចរាល់ហើយ ទើបសុំលេខទូរស័ព្ទទំនាក់ទំនង ហៅឱ្យចូលរួមសកម្មភាពនិងកម្មវិធីរបស់រ៉ក់បន្ត ក្នុងនាមជាសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ ប៉ាជាភ្នាក់ងារមួយដែលបានសាងសង់ខ្សែបណ្តាញនៃសមាជិកទុកឱ្យអ្នកជំនាន់ក្រោយ

បានទៅទាក់ទងបន្ត ដើម្បីពង្រឹងទំនាក់ទំនង និងទំនុកចិត្ត ហើយអ្នកខ្លះក៏ឈានទៅទទួលកិច្ចការជាសមាជិកសកម្មរបស់រ៉ក់ទៀតផង។ ក្រុមសមាជិកសកម្ម គឺជាក្រុមចូលរួមចងក្រងសហគមន៍ និងសកម្មភាពតស៊ូមតិ ដើម្បីទទួលបានការឆ្លើយតបចំពោះតម្រូវការចាំបាច់របស់ខ្លួន គឺការទទួលបានការគោរព និងការការពារសិទ្ធិមនុស្សរបស់ខ្លួន ជៀសផុតពីការមាក់ងាយ និងរើសអើងឱ្យដូចទៅនឹងប្រជាពលរដ្ឋខ្មែរដទៃទៀត។



សកម្មភាព ចងក្រងសមាជិកអ្នកស្រឡាញ់ភេទដូចគ្នាឆ្នាំ២០១៦

រហូតមកដល់ពេលបច្ចុប្បន្ន ប៉ាសង្កេតមើលឃើញថាអ្នកស្រឡាញ់ភេទដូចគ្នាហ៊ានបញ្ចេញថាខ្លួនជាអ្នកស្រឡាញ់ភេទដូចគ្នា ហ៊ានទទួលស្គាល់ និងទទួលយកខ្លួនឯង ហើយក្លាហានចេញមុខ បង្ហាញពីអត្តសញ្ញាណយេនឌ័ររបស់ខ្លួន។ ប៉ាមានអារម្មណ៍សប្បាយរីករាយដែលបានចូលរួមចំណែក ដោយការចែករំលែកពីសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នាទៅកាន់អ្នកដទៃ ពិសេសសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាផ្ទាល់ ឱ្យដឹងពីសិទ្ធិរបស់ខ្លួន និងមានភាពក្លាហានជាងមុន។

វាគឺជាការពិត ដែលវត្តមានរបស់ប៉ាសាញ់ គឺជាផ្នែកមួយដ៏សំខាន់នៃការចូលរួមកសាងសហគមន៍រ៉ក់ ដែលយើងជាអ្នកជំនាន់ក្រោយទទួលស្គាល់ គោរព និងស្រឡាញ់ចំពោះការជួយត្រួសត្រាយ ហើយបើកផ្លូវឱ្យពួកយើងធ្វើកិច្ចការងារបន្ត ដើម្បីទទួលបានជោគជ័យនៃគោលបំណងរួមរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា គឺរស់នៅបើកចំហ ដោយរីករាយ សុខសាន្ត ហើយស្មើភាពគ្នានាពេលបច្ចុប្បន្ន និងអនាគត។



# មី៉ុ ចាន់ថន ( ឈ្មោះផ្លូវការ ទិត្យ ម៉ាន់ )

ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស រស់នៅស្រុកបាកាន
ខេត្តពោធិ៍សាត់



រូបថតតាថន កាលពីឆ្នាំ២០១២

លោកតាថន ជារៀមច្បងរបស់រ៉ក់មួយរូបទៀត ដែលបានកើតនៅក្នុងឆ្នាំ១៩៥១ និងបានឆ្លងកាត់ការផ្លាស់ប្តូររបបសង្គមជាច្រើនមកហើយ។ គាត់កំណត់ខ្លួនជាបុរស ហើយបានកាត់សក់ខ្លី និងចូលចិត្តស្លៀកខោ តាំងពីអាយុ៨ឆ្នាំមកម្ល៉េះ។ តែការតុបតែងខ្លួននោះ គឺជាចំណង់ចំណូលចិត្តផ្ទាល់ខ្លួន ដោយមិនគិតថាខ្លួនជាបុរសទេ។

ពេលទៅរៀន គាត់តែងស្លៀកខោប៉ោងជើង និងមានសំពត់ដាក់តាមកាតាបត្រៀមជានិច្ច។

សំណាងដែរ គាត់មានគ្រូបង្រៀនចិត្តល្អម្នាក់មិនដែលហាមឃាត់ការស្លៀកពាក់របស់គាត់ ឬមានពាក្យចោទប្រកាន់ថាមិនសមរម្យឡើយ។ តាតែងតែស្លៀកបែបនេះរហូតឈានដល់វ័យ២០ឆ្នាំជាងដែលតាចាប់ចិត្តស្រឡាញ់ស្ត្រីម្នាក់ ហើយបានរស់នៅជាមួយគ្នា ក្នុងនាមជាភរិយារហូតមកដល់សព្វថ្ងៃ ទើបតាច្បាស់ចិត្តថាខ្លួនមានភេទស្រីតែមានបេះដូងជាបុរស។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬជំនាន់ប៉ុលពត ដែលជារបបរស់នៅបែបសមូហភាព និងមានការជម្លៀសប្រជាជន ក៏បាននាំភរិយារបស់គាត់គឺលោកយាយថុល ចាកចេញពីស្រុកកំណើត មកជួបគ្នានៅស្រុកបាកាន ខេត្តពោធិ៍សាត់។ ពួកគាត់បានស្នាក់អាស្រ័យជាមួយគ្នា ដោយតាមានតួនាទីជាអ្នកភ្ជួររាស់ស្រែ រីឯយាយជាអ្នកដាំបាយនៅផ្នែកចុងភៅ។ តារំលឹកឡើងថា៖ « *មេកងតែងលាន់មាត់ឆ្ងល់ថា គាត់ទាំងពីរនេះជាមិត្តភក្តិទេ តែកៀកកើយ មើលថៃគ្នាដូចប្តីប្រពន្ធ។* »

ពេលគេបំបែកក្រុមទៅកន្លែងផ្សេង យាយរមែងសុំទៅជាមួយ ប៉ុន្តែក៏មិនមានអ្នកណាមានចំណាប់ការអ្វីពីរឿងពួកគាត់ទាំងពីរនាក់ដែរ។ លុះដល់ចប់សម័យខ្មែរក្រហម អ្នកទាំងពីរក៏បែកគ្នា ដែលលោកតាចល័តទៅរកស៊ី ពីខេត្តពោធិ៍សាត់ទៅដល់ខេត្តផ្សេងៗទៀត។

ដល់ពេលមួយ តាចាប់ផ្តើមរកស៊ីជួញក្រណាត់ និងបន្លែ ដោយក្រែងរកចំណូលគ្រាន់បើជាងមុន ហើយក៏បានសម្រេចចិត្តថាទៅរាជធានីភ្នំពេញ។ តែពេលទៅដល់ តាក៏ធ្វើដំណើរបន្តចូលទៅស្រុកបាទី ខេត្តតាកែវ ទៅស្វែងរកផ្ទះយាយថុល ទាល់តែបានជួបយាយ និងស្គាល់

ផ្ទះច្បាស់លាស់ ទើបគាត់ក៏ត្រឡប់មកភ្នំពេញវិញ។ ក្រោយមកមួយរយៈ ទើបតាថនបបួលមិត្តភក្តិជិតស្និទ្ធ៤ទៅ៥នាក់ទៀត ទៅទទួលយាយមករស់នៅភ្នំពេញជាមួយគ្នា។ អ្នកទាំងពីរបានមករស់នៅភ្នំពេញ ដោយតាចេះលក់ដូរស្រាប់ រីឯយាយក៏រៀនដែរ ហើយអ្នកទាំងពីរជួញជាមួយគ្នា ពង្រីកមុខរបរឱ្យកាន់តែរីកចម្រើន។ ទម្រាំតែនិយាយគ្នាត្រូវរ៉ូវ និងបានរួមរស់ចាប់ដៃគ្នាមកដល់បច្ចុប្បន្ន គាត់ទាំងពីរត្រូវប្រឈមឧបសគ្គនៃការបំបែកបំបាក់ពីក្រុមគ្រួសារ និងសាច់ញាតិជាទីស្រឡាញ់ ស្របនឹងយាយមានជម្ងឺប្រចាំកាយទៀតផង។ តាមិនបានបោះបង់យាយនោះទេ គឺនៅមើលថែទាំយាយ ដោយអំណាចទឹកចិត្តស្រឡាញ់ និងអាណិត ដែលធ្វើឱ្យពួកគាត់តស៊ូជម្នះរាល់ឧបសគ្គទាំងអស់បាន។



រូបថតយាយថុល និងតាថន ឆ្នាំ២០១៦

តាថនស្គាល់ និងមានក្លើជិតស្និទ្ធគឺ លោក ណយ ស៊ីថា ដែលតាំងខ្លួនជាបុរសដូចគាត់ដែរនៅក្នុងជំនាន់ប៉ុលពត។ ការមានគ្នាបែបនេះ ក៏ផ្តល់ភាពក្លាហានខ្លះៗ ឱ្យតាអាចធ្វើជាខ្លួនឯងដោយសុខស្រួលជាងមុនបន្តិច។ ភាតរភាពនេះ ក៏ជាចំណែកនៃការចងគ្នាជាមិត្ត និងជាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា រហូតបង្ហាញវត្តមាននៅក្នុងសង្គមខ្មែរ ជាបន្តបន្ទាប់មកដល់សព្វថ្ងៃ។ ប៉ាស៊ីថា ក៏បានទំនាក់ទំនងជាមួយតាថន ជានិច្ចជាកាល និងបានអញ្ជើញគាត់

ឱ្យចូលរួមការជួបជុំជាមួយអង្គការបណ្ដាញការងារស្ត្រីរួបរួមគ្នា។ ក្រោយមក ប៉ាស៊ីថា បានណែនាំតា អំពីសហគមន៍ឥន្ទធនូកម្ពុជា ថាជាអង្គការដែលធ្វើការលើរឿងអ្នកស្រឡាញ់ភេទដូចគ្នា និងចង់អញ្ជើញតាឱ្យចូលរួមក្នុងកម្មវិធីជួបជុំគ្នានៅភ្នំពេញ។ នៅពេលឃើញអ្នកដែលមានអត្តសញ្ញាណដូចខ្លួនជាច្រើន ហើយអាចចេញមុខពេញលេញ ក្នុងការប្រជុំនោះ បានផ្ដល់ក្ដីសង្ឃឹម និងភាពក្លាហានមួយជំហានទៀត ឱ្យតាអាចចេញមុខជាអ្នកប្ដូរយេនឌ័រជាបុរស។ តាបានរំលឹកពីគ្រានោះថា៖ « *ខ្ញុំគិតក្នុងចិត្តថា ចាប់ពីពេលនេះទៅ អ្នកស្រឡាញ់ភេទដូចគ្នាមានសេរីភាព សិទ្ធិដើរហើរ ហើយក្មេងៗមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ សុំកូន និងធ្វើលិខិតអាត្រានុកូលដ្ឋានបានហើយ។* »



ប្រគេនតេយ្យទាន ជូនព្រះសង្ឃ ក្នុងឱកាសសប្ដាហ៍មោទនភាពអ្នកស្រឡាញ់ភេទដូចគ្នា ឆ្នាំ២០១៦

ក្នុងឆ្នាំ២០១៣ តាបានចាប់ផ្ដើមចងក្រងសមាជិក ដោយទំនាក់ទំនងអ្នកដែលមើលទៅមានរូបរាង និងអត្តចរិតដូចគាត់។ គាត់ព្យាយាមសង្កេត ទៅសាកសួរ សុំលេខទូរស័ព្ទ និងជំរុញឱ្យពួកគេចូលរួមកម្មវិធីរបស់រ៉ក់នៅភ្នំពេញ ដើម្បីឱ្យពួកគេមានសំឡេង។ តាក៏បានផ្សារភ្ជាប់ទំនាក់ទំនង និងរៀបចំសិក្ខាសាលាអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាជាមួយអាជ្ញាធរក្នុងឃុំរបស់គាត់ និងឃុំដែលជិតនោះផងដែរ។ អ្វីដែលជាឧបសគ្គកាលពី១០ឆ្នាំមុនគឺ សមាជិក

ដែលបានចងក្រង ហើយឧស្សាហ៍ប្តូរលេខទូរស័ព្ទជាញឹកញាប់។ ដូច្នេះតាក៏ត្រូវដើរស្វែងរក និងចុះទៅជួបម្តង ហើយម្តងទៀត ដើម្បីអាចរក្សាទំនាក់ទំនងជាមួយគ្នាបាន។ កត្តាដែលជំរុញចិត្តឱ្យគាត់ចងក្រងសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងភូមិស្រុក គឺការឆ្លុះពីបទពិសោធន៍ខ្លួន ដែលធ្លាប់ឆ្លងកាត់ ដែលជួបការលំបាក អាចពឹងពាក់ទៅមករកគ្នាបាន។ ជាក់ស្តែង ពេលមានឪពុកម្តាយបំបែកកូនៗ ដែលរស់នៅជាមួយគ្នា តាបានទៅជួបពួកគាត់ និយាយពន្យល់ហេតុផល និងចែករំលែកនូវសាច់រឿង និងបទពិសោធន៍ដែលធ្លាប់ឆ្លងកាត់កាលនៅក្មេង។ ការណ៍នេះបានជំរុញទឹកចិត្តឪពុកម្តាយទាំងសងខាងឱ្យទទួលយក និងអនុញ្ញាតឱ្យកូនទាំងពីររួមរស់នៅជាមួយគ្នាជាគូស្រករ។

បានរួមដំណើរជាមួយរ៉ក់អស់រយៈពេល១៨ឆ្នាំកន្លងមកនេះ ក្តីសង្ឃឹមរបស់តា ចេះតែកើនឡើងម្តងបន្តិចៗ៖ « *ខ្ញុំឃើញថាអង្គការរ៉ក់ជាអ្នកដឹកនាំដ៏រឹងមាំ មានការគាំទ្រពីមួយថ្នាក់ ទៅមួយថ្នាក់ ចាប់ពីអាជ្ញាធរមូលដ្ឋានរហូតដល់ថ្នាក់ជាតិ។ ខ្ញុំសង្កេតឃើញ ហើយកោតសរសើរបំផុតនោះ គឺការដឹកនាំរបស់រ៉ក់មានការស្រុះគ្នា ចេះផ្តល់យោបល់ ឱ្យគ្នាទៅវិញទៅមក មានភាពម៉ឺងម៉ាត់ ហើយថែមទាំងក្លាហានហ៊ានជជែកជាមួយរាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់។*»

ការរៀបការមិនមែនជាតម្រូវការសំខាន់របស់តា និងយាយទេ ព្រោះតាយាយចាស់ៗណាស់ទៅហើយ ប៉ុន្តែតានៅតែតាំងចិត្តបន្តចូលរួមតស៊ូ ដោយផ្តល់កម្លាំងចិត្តទៅក្មេងៗជំនាន់ក្រោយ ដើម្បីទទួលបានច្បាប់អាពាហ៍ពិពាហ៍ស្មើភាពគ្នា សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាដោយពេញលេញពិតប្រាកដ។ តាក៏សង្ឃឹមដែរថា ពួកគេប្រើប្រាស់សិទ្ធិសេរីភាពរបស់ពួកគេឱ្យបានត្រឹមត្រូវ មានការត្រិះរិះពិចារណា និងគិតគូរឱ្យបានច្បាស់លាស់ នៅពេលជ្រើសរើសដៃគូ មុនដាក់ការតាំងចិត្តថានឹងរៀបការ ហើយកសាងគ្រួសារជាមួយគ្នា។

ក្នុងនាមជាព្រឹទ្ធាចារ្យមួយរូប ដែលបានជួយកសាង និងជ្រោមជ្រែងសហគមន៍រ៉ក់ ថ្វីត្បិតតែមានវ័យកាន់តែចាស់ ហើយសុខភាពចុះខ្សោយ តែឆន្ទៈរបស់តា នៅតែមុតមាំជានិច្ចក្នុងការបន្តចូលរួមគាំទ្រ ផ្តល់កម្លាំងចិត្ត និងផ្តល់ដំបូន្មានល្អៗ ដល់សមាជិកសហគមន៍រ៉ក់ជំនាន់ក្រោយ ដែលបានបញ្ជាក់ពីភាពសកម្មរបស់តាដ៏មានតម្លៃបំផុត។




រូបថតរបស់លោកតាម៉ី ចាន់ថន ជាមួយអាជ្ញាធរមូលដ្ឋានស្រុកបាកាន ឆ្នាំ២០១៩



# ឌុល ចុល

ជាស្ត្រីស្រឡាញ់ស្ត្រី រស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់

លោកយាយឌុល ថុល មានអាយុ៧៣ឆ្នាំ ( កើតឆ្នាំ១៩៥០ ) មានភេទកំណើតជាស្រី និង អត្តសញ្ញាណយេនឌ័រជាស្ត្រី។ យាយមានស្រុកកំណើតនៅស្រុកបាទី ខេត្តតាកែវ តែយាយ បានមករស់នៅជាមួយតាម៉ាន់ ដែលមានឈ្មោះហៅក្រៅ « តាថន » ក្នុងស្រុកបាកាន ខេត្ត ពោធិ៍សាត់ ចាប់តាំងពីឆ្នាំ២០០០ រហូតដល់បច្ចុប្បន្ននេះ។ យើងពិតជាចាប់អារម្មណ៍ដោយ ជួនកាល យាយ ថុល ហៅ តា ថន ថា យាយម៉ាន់ ហើយពេលខ្លះហៅថា តា ថន។ យាយ និង ខ្ញុំកំពុងអង្គុយជជែកគ្នានៅលើគ្រែ ដែលមានអាយុ២០ឆ្នាំជាងហើយ ដែលជាឈើសល់ពីផ្ទះ ចាស់របស់យាយ និងតាកាលពីពេលដែលពួកគាត់ទាំងពីរនាក់ បានមករស់នៅរាជធានីភ្នំពេញ មក ម្ល៉េះ។ យាយញញឹមបណ្ដើររៀបរាប់បណ្ដើរថា៖ « *នៅសម័យយាយ ធំដឹងក្ដីមិនទាន់ទេ ចាស់ទុំ តែងគិតគូររៀបចំគូស្រករឱ្យហើយជាស្រេច ភាគច្រើនជាអ្នកនៅក្នុងស្រុកភូមិ ឬបង ប្អូននឹងគ្នាផង ព្រោះចាស់ៗគិតថាកុំឱ្យបែកទ្រព្យ និងវង្សត្រកូល។* » ពេលស្ដាប់ដល់ចំណុច នេះ ធ្វើឱ្យខ្ញុំនឹកគិតដល់ពាក្យចាស់ពោលថា « ជួញជិតប្រសើរ ជាងជួញឆ្ងាយ » ។ ត្រឡប់មក សាច់រឿងយាយវិញ នៅទសវត្ស៍១៩៦០ ក្នុងវ័យប្រមាណ១០ឆ្នាំជាង ពេលនោះយាយធំ ពេញវ័យ ហើយមិនទាន់បានប៉ុន្មានឆ្នាំផង សង្គ្រាមស៊ីវិលក៏បានចូលមកដល់ គឺចាប់ពីឆ្នាំ១៩៧០ ដល់១៩៧៥ ដែលជាសម័យសាធារណរដ្ឋខ្មែរ ឬប្រជាជនខ្មែរស្គាល់ថា សម័យរដ្ឋប្រហារ ដឹកនាំដោយលោកលន់ នល់ ហើយបន្ទាប់មកឈានចូលរបបកម្ពុជាប្រជាធិបតេយ្យ ឬរបប ប៉ុល ពត ឬខ្មែរក្រហម។ គ្រប់គ្នាត្រូវបានជម្លៀសចេញឆ្ងាយពីស្រុកកំណើត បែកគ្រួសារបងប្អូន និងកូនចៅរបស់ខ្លួន។ យាយថុល ក៏ត្រូវបានខ្មែរក្រហមជម្លៀសពីស្រុកកំណើត ឱ្យទៅរស់នៅ ខេត្តពោធិ៍សាត់។ ពេលនោះហើយ ដែលយាយបានជួបនឹងដៃគូរបស់គាត់សព្វថ្ងៃ គឺតាថន ជាលើកដំបូង។ តាយាយ មានភាពស្និទ្ធស្នាល និងបារម្ភពីគ្នាណាស់ មិនចង់ទៅណាបែកឆ្ងាយ ពីគ្នាឡើយ ទោះគេជម្លៀសទៅណា ក៏មិនចង់ទៅដែរ។

បន្ទាប់ពីសង្គ្រាមចប់សព្វគ្រប់ នាដើមទសវត្ស៍១៩៨០ យាយបានត្រឡប់ទៅស្រុកកំណើត ឯស្រុកបាទី ខេត្តតាកែវវិញ ដោយក្នុងចិត្តនឹករំពឹងថានឹងបានជួបជុំបងប្អូនកូនចៅខ្លួនវិញ តែ គ្រប់យ៉ាងមិនដូចការរំពឹងទុកឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏យាយនៅតែបន្តជីវភាពថ្មី លើទឹកដីកំណើតរបស់ខ្លួន។ ពេលនោះ មានប្រជាពលរដ្ឋច្រើនបោះឆ្នោតជ្រើសរើសឱ្យគាត់ ចូលបម្រើការងារ ផ្នែកសេដ្ឋកិច្ចក្នុងឃុំរបស់គាត់។ តួនាទីនោះ គឺត្រូវបើកអង្ករ និងស្បៀង

អាហារជូនប្រជាជនដែលខ្វះខាត ក្រោយពីបែកពីរបបខ្មែរក្រហម។ បើយើងគិតទៅ យាយមានសមត្ថភាពមិនធម្មតាឡើយ ព្រោះមិនងាយឯណា ជាមនុស្សស្រីវ័យ២០ឆ្នាំជាង ទៅធ្វើការក្នុងសាលាឃុំបែបនេះទេនៅសម័យនោះ។



រូបថតតាថន យាយថុល ឆ្នាំ២០២០

បើនិយាយពីអ្នកចង់បានយាយធ្វើជាគូគ្រង នៅពេលនោះវិញ គឺមិនខ្វះទេ តែយាយមិនព្រម។ ស្របពេលដែលយាយកំពុងធ្វើការនៅស្រុកកំណើត តាថនក៏កំពុងព្យាយាមស៊ើបសួរគ្រប់ច្រកល្ហក ពីដំណឹងរបស់យាយដែរ។ ស្រាប់តែថ្ងៃមួយ តាបានដឹងពីការងារ និងស្គាល់ផ្ទះរបស់យាយ ក៏ធ្វើដំណើរទៅរកទាំងសប្បាយចិត្ត ព្រោះចិត្តប្រតិព័ទ្ធលើយាយតាំងពីបានជួបគ្នាក្នុងគ្រាសង្គ្រាមមកនោះនៅតែមានដដែល។ ដល់ត្រង់នេះយាយរៀបរាប់បណ្តើរ ញញឹមបណ្តើរ ភ្នែកសម្លឹងទៅទេសភាពជុំវិញផ្ទះ ព្រោះតែអៀនកូន ដែលកំពុងស្តាប់។ ចំណែកងដៃវិញ នៅមិនស្ងៀមឡើយ ឆ្កឹះកន្ទេលហើយពត់ខ្លួនចុះឡើង ដោយហេតុចុករោយផងនោះ យាយបាននិទានបន្តថា៖ « *កូនអើយ...ស្រាប់តែថ្ងៃមួយ យាយម៉ាន់ ទៅរកខ្ញុំដល់ផ្ទះ ដោយខ្ញុំមិនដឹងដំណឹងមុនសូម្បីតែបន្តិច។ គាត់បានសួរយាយត្រង់ៗថា ព្រមទៅរស់នៅរកស៊ី ជុំគ្នា*

*ជាមួយគាត់ ឬអត់។ ខ្ញុំក៏ឆ្លើយថា ខ្ញុំនៅជួបជុំជាមួយបងប្អូន នៅស្រុកកំណើតនេះហើយ មិនទៅណាទេ។* » នៅពេលនោះហាក់មានការមិនពេញចិត្តពីសំណាក់សាច់ញាតិខាងយាយដែរ។ ក្រោយនិយាយគ្នាចប់សព្វគ្រប់ យាយម៉ាន់ ក៏ព្រមត្រឡប់មកភ្នំពេញវិញ ព្រោះគាត់នៅរកស៊ីជួញដូរក្រណាត់ និងបោះដុំបន្លែ នៅទីក្រុងភ្នំពេញនៅឡើយ។ យាយក៏នឹកក្នុងចិត្តថា ប្រហែលជាស្វាត់បាត់ឈឹងហើយ មានឯណាស្រាប់តែកន្លះខែក្រោយមក យាយម៉ាន់ និងមិត្តភក្តិគាត់បីបួននាក់ នាំគ្នាទៅហៅគាត់ស្វាត់ៗទាំងកណ្តាលអធ្រាត្រ មិនឱ្យអ្នកណាដឹងទេ។ គាត់បានសួរខ្ញុំថា តើព្រមទៅរស់នៅ រកស៊ីជួបជុំគ្នា ជាមួយគាត់នៅក្រុងឬអត់? យាយក៏ព្រមទៅតាមតា ដោយស្ងាត់ៗ មិនប្រាប់អ្នកផ្ទះឡើយ។ យាយរៀបរាប់បណ្តើរ សើចបណ្តើរ ដោយនឹកហួសចិត្ត នឹងខ្លួនឯងកាលនោះ។

អ្នកទាំងពីរ ក៏បានមករស់នៅជុំគ្នា មានមុខរបររកស៊ី ហើយមានបានណាស់កាលនោះ មានទាំងផ្ទះខ្លួនឯងនៅម្តុំពេទ្យចិនផង។ ក្រោយមកពួកគាត់ ក៏ជួបឧបទ្ទវហេតុភ្លើងឆេះផ្ទះ។ បន្ទាប់ពីនោះ ក៏មានមីងម្នាក់ ដែលរាប់អានគ្នាដូចសាច់ញាតិបង្កើត បានទិញផ្ទះនៅជាប់ទូតអាមេរិកចាស់ឱ្យរស់នៅ។ យាយបានរៀបរាប់ទៀតថា៖ « *ផ្ទះពីរជាន់ ឈើលើថ្មក្រោម ម្ខាងជាប់ទូតអាមេរិកចាស់ ម្ខាងទៀតជិតផ្ទះវីឡារបស់អ្នកមានវង្សត្រកូលខ្សែខ្ពង់ខ្ពស់ដែរ។* » ក្រៅពីមុខរបររកស៊ី កាលនោះតាយាយមានគ្រែចំនួនប្រាំមួយ ដាក់ជួលឱ្យគេលក់បន្លែនៅផ្សារបឹងកេងកង ហើយយាយធ្វើបាយម្ហូបប្រចាំខែ សម្រាប់អ្នកធ្វើការនៅទូតដែរ យាយ និងតារកស៊ីកាក់កបណាស់។ រហូតដល់អាយុ៤០ឆ្នាំ យាយក៏បានចាប់ផ្តើមធ្លាក់ខ្លួនឈឺ ហើយប្រើប្រាស់ទ្រព្យធន លុយកាក់ ដែលរកបានទាំងប៉ុន្មាន យកទៅព្យាបាលជំងឺអស់។ យាយព្យាបាលជំងឺតាំងពីស្រុកខ្មែរ ដល់ស្រុកព្រៃនគរ នៃប្រទេសវៀតណាម ក៏នៅតែមិនធូរស្បើយ។ ដល់ចំណុចនេះ ខ្ញុំជាអ្នកស្តាប់សែនស្ញប់ស្ញែងនឹងក្តីស្រឡាញ់ ស្មោះស្ម័គ្ររបស់យាយតាទាំងពីរ ដែលនៅមើលថែរក្សាគ្នា ទាំងឈឺជា មានក្រលំបាកយ៉ាងណា ក៏មិនបោះបង់គ្នាចោល។ នៅឆ្នាំ២០០០ ស្រាប់តែអ្នកទាំងពីរត្រូវត្រឡប់មករស់នៅស្រុកកំណើតខាងតាថនវិញ ព្រោះមិនមានអ្នកណានៅមើលថែម្តាយរបស់តាថន ដែលមានវ័យចាស់ជរា ហើយកាលនោះ យាយកំពុងតែមានជំងឺជាប់ខ្លួន មិនទាន់ទាំងជាសះស្បើយនៅឡើយផង។ មកនៅដំបូងៗ ក៏មិនទាន់មានផ្ទះស្រួលបួលដែរ គឺនៅខ្ទម ដែលសល់ពីសម័យខ្មែរក្រហម លើដីសព្វថ្ងៃ។ ហើយផ្ទះរាល់ថ្ងៃនេះ គឺបាន

អ្នកស្រុក អ្នកភូមិដែលខ្ញីគោមួយនឹម តែមិនមានលទ្ធភាពសងជាលុយដូចការព្រមព្រៀង ក៏គេសុំធ្វើជាផ្ទះនេះឱ្យជំនួសការសងជាលុយវិញ។



រូបថតកូនៗ ក្នុងសហគមន៍ទៅលេង យាយតានៅក្នុង ឆ្នាំ២០២០

ពួកគាត់បន្តរស់នៅទីនោះ ដោយយាយដាំបន្លែ ចិញ្ចឹមមាន់ និងជ្រូកជាមុខរបរចិញ្ចឹមជីវិតបែបស្រុកស្រែចំការម្តង។ មុខរបរថ្មីនេះ ធ្វើឱ្យគ្រួសារតាយាយហាក់មានចំណូលគួរសម ជីវភាពគាត់បានប្រសើរជាងមុនមួយកម្រិត ហើយសុខភាពរបស់គាត់ ក៏បានស្រាកស្រាន្តដែរ។ សព្វថ្ងៃគាត់សម្រាកពីកិច្ចការទាំងនោះហើយ នៅមើលថែផ្ទះ និងចិត្តផ្តោតសំខាន់តែទៅវត្តធ្វើបុណ្យទានពីរនាក់យាយតា ដោយប្រាថ្នា តែសេចក្តីស្ងប់សុខប៉ុណ្ណោះ។ យាយមិនដែលភ្លេចញញឹមឡើយនៅពេលនិទានសាច់រឿងនេះប្រាប់ខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ជីវិតគូក្រសកររបស់យាយតាទាំងពីររស់នៅជុំគ្នាក៏មិនខុសអីពីប្តីប្រពន្ធផ្សេងទៀតដែរ តែងមានឡើងចុះ ប៉ះទង្គិចគ្នា ដូចពាក្យចាស់ពោលថា « *ចានក្នុងរាវ រមែងអីតែងមានការប៉ះគ្នា* »។ អ្វីដែលសំខាន់នោះគឺអ្នកទាំងសងខាងចេះយោគយល់ និងអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក។

ខ្ញុំបានសួរសំណួរទៅគាត់ថា៖ « *តើយាយចាំទេថាស្គាល់រ៉ក់ ដែលជាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាតាំងពីពេលណាមក ?*» យាយក៏សើចសម្លឹងមកខ្ញុំតបថា៖ « *អត់ចាំទេចៅ ហិហិ* »

យើងក៏សើចព្វៗព្រមគ្នា។ យាយពិតជាត្រង់មែន បើមិនចាំ ថាមិនចាំ។ ខ្ញុំក៏សួរថែមទៀតថា៖ « *ចុះយាយមានចាំថា យាយធ្លាប់ទៅចូលរួមកម្មវិធីជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅភ្នំពេញទេ?* » យាយតប៖ « *យាយធ្លាប់ទៅដែរពីដើម តែមិនដឹងឆ្នាំណាទេ ហើយជួបអ្នកណាក៏មិនសូវជាចាំដែរ តែដឹងថាប្រហែលបានទៅចូលរួមកម្មវិធីសហគមន៍បានបីដងដែរ។* » ដោយទាល់មិនដឹងសួរយ៉ាងម៉េចទៀត ខ្ញុំក៏ជួយរំលឹកយាយ កាលពីទៅជុំគ្នានៅសៀមរាបកាលឆ្នាំ២០១៩ ពេលយើងធ្វើការពិគ្រោះយោបល់សមាជិកតាមភូមិភាគ យាយក៏ចាំភ្លាម ព្រោះវាជាលើកទីមួយក្នុងជីវិតយាយ ដែលបានទៅដល់ទឹកដីអង្គរ និងបានឃើញបានប៉ះប្រាង្គប្រាសាទអង្គរវត្តទៀតផង។ ក្រៅពីអនុស្សាវរីយ៍ខាងលើ យាយក៏បានលើកពីសមាជិក សហគមន៍ ដែលធ្លាប់ទៅលេង និងស្នាក់នៅផ្ទះគាត់ ដែលក្នុងចំណោមនោះ គាត់នឹកឃើញសមាជិកសកម្មម្នាក់ គឺម៉ែឈឿន ជាអ្នកខេត្តកំពង់ធំ។ យាយចងចាំបំផុតពីម៉ែឈឿន គឺភាពក្លាហាន និងទេពកោសល្យ ពូកែនិយាយស្ដី ដូចនេះហើយយាយតែងនឹករលឹក និងសួរពីសុខទុក្ខគាត់ ដូចជាសាច់ញាតិម្នាក់ដែរ។ ឥឡូវយាយចាស់ហើយឈឺច្រើន ពិបាកធ្វើដំណើរ ដោយចុករោយ វិលមុខ ទៅណាមិនសូវបានឆ្ងាយទេ ទាំងចិត្តនៅតែចង់ទៅជួបជុំកូនចៅដែល ជាសហគមន៍រ៉ក់ ពេលមានកម្មវិធីជួបជុំគ្នាម្ដងៗ។



រូបថតយាយថុល ក្នុងសិក្ខាសាលាជាមួយសមាជិករ៉ក់ ក្នុងភូមិភាគឧត្តរ ឆ្នាំ២០១៩

ដូចនេះហើយកូនចៅនៃសហគមន៍រ៉ក់ ក៏បានទៅលេង ជួបសួរសុខទុក្ខចាស់ទុំទាំងទ្វេរិញ ដូចជាអ្នកនៅភ្នំពេញ និងអ្នកនៅខេត្តកំពង់ឆ្នាំងជាដើម។ កូនចៅដែលជាសមាជិកសហគមន៍ ដែលរស់នៅក្នុងភូមិជិតៗគ្នាដូចជា ម៉ាប់ ឡុង និងដៃគូរបស់ពួកគេ ដែលតាថនបានចងក្រង ជាសមាជិក ក៏ឧស្សាហ៍មកលេង សួរសុខទុក្ខ និងសុំយោបល់ពីតាយាយ ជាចាស់ព្រឹទ្ធាចារ្យ ផងដែរ។

សាច់រឿងលោកយាយថុល ពិតជាសាក្ខីភាពនៃវត្តមានស្ត្រីស្រឡាញ់ភេទដូចគ្នាខ្មែរមួយរូប ដែលបានរស់នៅឆ្លងកាត់របត់ជីវិត និងរបបសង្គមពីមួយជំនាន់ទៅមួយជំនាន់ ហើយមានក្តីស្រឡាញ់ ដែលធំធេងមហិមា ឥតលក្ខខណ្ឌ និងពុះពាររាល់ឧបសគ្គ ជាមួយតាថនរហូតដល់ចាស់កោងខ្នង។ ទាំងនេះ គឺជាបទពិសោធន៍ និងមេរៀនជីវិត ដែលអ្នកជំនាន់ក្រោយអាចឆ្លុះបញ្ចាំង សម្រាប់ការរៀនសូត្រផ្ទាល់ខ្លួនបាន ក្នុងការកសាងជីវិតគូស្រករ និងគ្រួសារ។



រូបថតតាថន និងយាយថុល ថតជុំកូនៗក្នុងសហគមន៍ ឆ្នាំ២០១៨



# ហិន ឈឿន ឬ ម៉ែឈឿន

ជាស្ត្រីស្រឡាញ់ស្ត្រី រស់នៅស្រុកស្ទឹងសែន ខេត្តកំពង់ធំ

ហ៊ន ឈឿន ឬម៉ែឈឿន កំណត់ខ្លួនជាស្ត្រីស្រឡាញ់ស្ត្រី កើតក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ ហើយបានរស់នៅទីនោះរហូតមកដល់ពេលបច្ចុប្បន្ន។ ក្នុងពេលលូតលាស់ពេញវ័យ ម៉ែផ្តោតតែលើការរកប្រាក់ចិញ្ចឹមឪពុកម្តាយ ដោយមិនយកចិត្តទុកដាក់លើការមានគូស្រករឡើយ បើទោះជាមានអ្នកចូលស្តីដណ្តឹងគាត់ច្រើនក៏ដោយ។ នៅទស្សវត្សរ៍១៩៨០ ម៉ែមានអាយុ២៧ឆ្នាំ គាត់ក៏ចេះមានចិត្តស្រឡាញ់លើប៉ាចន អាយុ៣៧ឆ្នាំ ស្លៀកពាក់រៀបចំខ្លួនជាបុរស មានសក់ខ្លីត្រឹមក។ ម៉ែឈឿន បានសុំប៉ាឱ្យជួយច្រូតស្រូវគាត់ ដែលបង្កើតជាឱកាសមើលចិត្តមើលថ្លើមគ្នា។ ម៉ែក៏បានមើលឃើញពីភាពស្លូតបូត តស៊ូ ហើយចេះជួយយកអាសារគេឯង ទើបម៉ែបាក់ចិត្តស្រឡាញ់ប៉ាចន ដោយមិនដែលនឹកស្មានថាគាត់នឹងអាចស្រឡាញ់ស្ត្រីដូចគ្នាទាល់តែសោះ។ គាត់ក៏បានគិតគូរព្រមព្រៀងចាប់ដៃរួមរស់ រកស៊ីចិញ្ចឹមជីវិត ហើយមើលថែគ្នារហូតដល់សព្វថ្ងៃ។ អ្នកជុំវិញ ទាំងក្រុមគ្រួសារ និងអ្នកភូមិមិនយល់ស្របនឹងទំនាក់ទំនងរបស់ពួកគាត់ទាំងពីរនាក់ទេ ជាពិសេសឪពុកម្តាយរបស់ម៉ែឈឿន ដែលយល់ថាពួកគាត់មិនអាចមានកូនចៅបន្តពូជពង្ស និងមិនអាចរកស៊ីចិញ្ចឹមជីវិតបានរីកចម្រើនឡើយ។ ពួកគាត់ទាំងពីរនៅតែបន្តជីវភាព និងធ្វើល្អចំពោះឪពុកម្តាយ ហើយតាំងចិត្តធ្វើជាគំរូឱ្យគេមើលឃើញពីការតស៊ូប្រឹងប្រែងរបស់ពួកគាត់វិញ។ គូស្រករទាំងពីរ បានកែប្រែការមាក់ងាយទាំងនេះ ឱ្យប្រែក្លាយជាការកោតសរសើរលើការរស់នៅរបស់ពួកគាត់រយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ប្រកបដោយសុភមង្គល និងចិត្តមេត្តាចំពោះគ្នា មានជីវភាពសមរម្យ ហើយធ្វើបុណ្យទាន ជាមួយអ្នកក្នុងភូមិស្រុកផងដែរ។



រូបថតម៉ែឈឿន និងក្រុមគ្រួសារ ក្នុងទសវត្សរ៍៩០

## ប្រវត្តិនៃការចូលរួមជាមួយសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)

ក្នុងឆ្នាំ២០១២ គាត់បានជួបជាមួយលោក ណយ ស៊ីថា ដែលជាអ្នកចងក្រងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៃអង្គការសហគមន៍ឥន្ទធនូកម្ពុជាតាមរយៈការណែនាំពីមិត្តភក្តិម្នាក់ ដែលជាអ្នកប្តូរយេនឌ័រជាបុរសម្នាក់ នៅភូមិជិតនោះឈ្មោះអ៊ំ អៀម។ នៅពេលឮដូចនេះ ម៉ែឈឿនក៏បានទៅជួប និងនិយាយរឿងរ៉ាវប្រវត្តិតស៊ូ នៃការចាប់ដៃគ្នា ហើយជម្នះឧបសគ្គកន្លងមកនោះ ទៅអ្នកចងក្រងសហគមន៍រ៉ក់ ហើយក៏ស្គាល់គ្នា បានទំនាក់ទំនង និងចូលរួមក្នុងកម្មវិធីសិទ្ធិមនុស្សអន្តរជាតិជាលើកដំបូង ដែលប្រារព្ធធ្វើនៅខណ្ឌទួលគោក រាជធានីភ្នំពេញ។ សម្រាប់ម៉ែឈឿន វាជាបទពិសោធន៍ដ៏រំភើប និងកក់ក្តៅមួយ ដែលគាត់មានឱកាសជួបអ្នកស្រឡាញ់ភេទដូចគ្នាច្រើននាក់ មកពីខេត្តផ្សេងៗខុសពីភូមិស្រុកគាត់ មិនសូវជាមានគ្នីគ្នាច្រើន ហើយគេមិនសូវមើលឃើញពីតម្លៃក្នុងភាពជាមនុស្ស។

ដោយសារតែអ៊ំ អៀម មានជម្ងឺប្រចាំកាយ ក្រុមងាររងាររ៉ក់ ក៏បានស្នើម៉ែឈឿនជួយចងក្រង និងទំនាក់ទំនងសមាជិកអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងភូមិស្រុករបស់គាត់ជាបន្ត។ ម៉ែលើកឡើងថា៖ «*អ្វីដែលធ្វើឱ្យខ្ញុំសម្រេចចិត្តចូលរួម និងធ្វើជាសមាជិកសកម្ម ព្រោះខ្ញុំជាអ្នកស្រឡាញ់ភេទដូចគ្នា ចង់រៀន និងចង់យល់ដឹងស៊ីជម្រៅ។ ហើយមួយវិញទៀត តាមការមើលឃើញការងាររ៉ក់ផ្ទាល់ រ៉ក់មានឆន្ទៈមោះមុត ដឹកនាំអ្នកស្រឡាញ់ភេទដូចគ្នាឱ្យដើរផ្លូវល្អ ឱ្យចេះស្គាល់គុណតម្លៃ និងមើលឃើញពីសមត្ថភាពខ្លួនឯង។*»



ម៉ែឈឿន និងតាចន ឆ្នាំ២០២៣

ក្នុងជំនួប និងការជជែកពិភាក្សាជាមួយសមាជិកសកម្ម អំពីការស្វែងរកដំណោះស្រាយ ដោយផ្តោតសំខាន់ទៅលើ ការមិនទទួលស្គាល់ និងការរើសអើងនៅមូលដ្ឋាន រួមមានការលំបាករបស់សមាជិករ៉ាក់ ដែលឪពុកម្តាយមិនទទួលស្គាល់។ ការចូលរួមដោយស្ម័គ្រចិត្តរបស់សមាជិកសកម្ម បានកំណត់តួនាទីខ្លួនជាចាស់ទុំផង និងជាផ្នែកមួយនៃដំណោះស្រាយផង តាំងចិត្តជួយអ្នកដែលកំពុងមានបញ្ហា។ ជាក់ស្តែងម៉ែឈឿន ត្រូវបានសមាជិកវ័យក្មេងចាប់ផ្តើមស្គាល់ និងជួបសួរយោបល់ពីការចេញមុខ ហើយព្យាយាមឱ្យគ្រួសារទទួលស្គាល់។ ក្នុងករណីខ្លះម៉ែឈឿន ក៏ទៅជួបនឹងឪពុកម្តាយរបស់ដៃគូផ្ទាល់ ដើម្បីជួយពន្យល់ ដោយលើកឧទាហរណ៍ចេញពីជីវិតជាក់ស្តែងរបស់គាត់ផងដែរ។ ពេលខ្លះ គាត់ក៏បានជួយរកការងារឱ្យក្មេងៗធ្វើនៅពេលគេមកសុំឱ្យគាត់ជួយ។ ក្នុងឆ្នាំ២០១៦ ម៉ែបានត្រួសត្រាយ និងនាំផ្លូវជាម្ចាស់ស្រុក និងចាស់ទុំ នាំក្រុមការងាររ៉ាក់ទៅជួបសំណេះសំណាល និងពិភាក្សាជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ ប៉ូលីសសង្កាត់ និងរដ្ឋបាលក្រុង អំពីលទ្ធភាពនៃការរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំណេះដឹងអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ សិក្ខាសាលានេះត្រូវបានរៀបចំនៅឆ្នាំ២០១៨ ដែលចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុងស្ទឹងសែន បានយល់ច្បាស់ពីហេតុផលដ៏ចាំបាច់ក្នុងការគាំទ្រសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ហើយថែមទាំងបានធ្វើសកម្មភាពផ្ទាល់ក្នុងសមាសភាពជាអាជ្ញាធរមូលដ្ឋានផង និងជាបុគ្គលផង។



សិក្ខាសាលា ពង្រឹងសហគមន៍ក្នុងការគាំទ្រដល់ អ្នកស្រឡាញ់ភេទដូចគ្នា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឆ្នាំ២០១៨

នៅដើមឆ្នាំ២០១៩ ម៉ែក៏បានមូលមតិជាមួយក្រុមការងាររ៉ក់ផ្តួចផ្តើម ដឹកនាំរៀបចំបុណ្យផ្កាសាមគ្គីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ទទួលសមាជិកមកពីខេត្តផ្សេងៗ ចាត់ចែងបច្ច័យដែលជាវិភាគទានរបស់សមាជិករ៉ក់ និងអ្នកភូមិ ដើម្បីយកទៅជួយកសាងវត្ត និងដោះទុក្ខផ្នែកជីវភាពមនុស្សចាស់ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នាកំពុងត្រូវការជំនួយដ៏ចាំបាច់។ ញាតិមិត្តភូមិផងរបងតែមួយ និងព្រះសង្ឃនៅតែលើកសរសើរថា សហគមន៍នេះចេះធ្វើបុណ្យទានតាមប្រពៃណី ទំនៀមទម្លាប់ និងសាសនា ដែលជាកិច្ចការល្អ ម៉ែបានជួយផ្តួចផ្តើមគំនិតដឹកនាំរួមគ្នាជាមួយសមាជិកឯទៀតគ្រប់ជំនាន់ ធ្វើឱ្យកម្មវិធីនេះ បានប្រព្រឹត្តទៅយ៉ាងអធិកអធម។ ម៉ែឈឿន រមែងចូលរួមសកម្មភាពនានារបស់រ៉ក់ ហើយក៏ទទួលបានការគាំទ្រមួយចំណែកពីប៉ាចន ដែលជាដៃគូជីវិតស្លាប់រស់ របស់គាត់ផងដែរ។ ម៉ែលើកឡើងថា៖

« *ពេលម៉ែទៅណាមកណា ទាំងមកចូលរួមជាមួយពួកកូនៗនៅរ៉ក់ក្តី ម៉ែតែងតែមានទំនុកចិត្ត ព្រោះតាចនយល់ថាអ្វីដែលម៉ែធ្វើ គឺជាការងារមានប្រយោជន៍ មិនដែលឃាត់ឃាំង ហើយក៏តែងជួយមើលថៃ ធ្វើការងារជំនួសម៉ែជានិច្ច។ គាត់សំខាន់ណាស់សម្រាប់ម៉ែ។* »



ការដង្ហែរផ្កាប្រាក់នៃបុណ្យផ្កាសាមគ្គីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា នៅខេត្តកំពង់ធំ ឆ្នាំ២០២០

គិតត្រឹមឆ្នាំ២០២៤នេះ ម៉ែឈឿនមានអាយុ៦៩ឆ្នាំហើយ តែម៉ែមានទឹកចិត្តរក្សាភាពសកម្មរបស់គាត់ ចូលរួម ក្នុងកម្មវិធីរបស់សហគមន៍រ៉ក់ ដើម្បីទទួលបានច្បាប់អាពាហ៍ពិពាហ៍ ធ្វើយ៉ាងណាឱ្យអ្នកស្រឡាញ់ភេទដូចគ្នាជំនាន់ក្រោយទទួលបានសិទ្ធិស្មើគ្នា។ គាត់ក៏សង្ឃឹមថា អ្នកជំនាន់ក្រោយនឹងមានភាពក្លាហាន និងមានទំនួលខុសត្រូវ ចំពោះតួនាទីខ្លួន និងរក្សាទឹកចិត្តរួបរួមសាមគ្គីជាធ្លុងមួយ នៅក្នុងសហគមន៍ ដោយមិនបោះបង់ចោលគ្នា។

## ចំណេះដឹង និងគន្លឹះដោះស្រាយជាផ្លែផ្កា

ម៉ែឈឿន៖ « *ពីដើមយើង មិនដែលដឹងថាយើងមានសិទ្ធិ និងច្បាប់ការពារ ហើយមានអ្នកណាគាំទ្រយើងឡើយ។ តែក្រោយមក យើងបានរៀនសូត្រពីមេធាវី យើងបានព្យាយាមរកគន្លឹះដោះស្រាយបញ្ហា ដូចជាការទៅរកឱ្យរាជរដ្ឋាភិបាលថ្នាក់ជាតិ និងអ្នកចេះដឹងឱ្យយល់ពីទុក្ខលំបាករបស់ពួកយើង ហើយជួយដោះស្រាយ។ យើងមានរ៉ក់មួយ ដែលប្រៀបដូចជាដើមឈើ ព្រោះយើងជាអ្នកស្រឡាញ់ភេទដូចគ្នា ដែលមាននៅ ២៥ខេត្ត/ក្រុង មិនឯកាទៀតទេ។ យើងជាកម្លាំង ដែលអាចទៅពឹងពាក់ និងឱ្យយោបល់គ្នា ដើម្បីសម្រេចគោលបំណងរឿងច្បាប់អាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាឱ្យបានជោគជ័យ។* »

ការគិតដោយវិជ្ជមាន ក្ដីសង្ឃឹម ថាមពល និងការប្រឹងប្រែងចូលរួម នូវរាល់សកម្មភាពរបស់ម៉ែឈឿន ជាមួយសមាជិកសហគមន៍រ៉ក់ដទៃទៀតទោះជិតឆ្ងាយ ញឹកញាប់ តិចថ្ងៃ ច្រើនថ្ងៃ ប៉ុណ្ណា ក៏ម៉ែមិនដែលត្អូញត្អែរ ពីការហត់នឿយម្ដងណាឡើយ។ ការលះបង់តស៊ូរបស់ម៉ែ ដើម្បីឱ្យសំឡេងរបស់អ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានស្ដាប់ឮ កាន់តែធំទូលំទូលាយ គឺជាគំរូដ៏មានតម្លៃយ៉ាងក្រៃលែង។



សកម្មភាពទៅសួរសុខទុក្ខចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាសង្កាត់អូរកន្សរ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឆ្នាំ២០១៩



# ផាង សាមីន

ជាស្ត្រីស្រឡាញ់ស្ត្រី រស់នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង



រូបថតម៉ែសាមីន អំឡុងទសវត្ស៩០

ផាង សាមីន កើតក្នុងឆ្នាំ១៩៦៣ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងរស់នៅទីនោះមកដល់ពេលបច្ចុប្បន្ន។ គាត់ជាស្ត្រីម្នាក់ដែលបានកំណត់ខ្លួនជាអ្នកស្រឡាញ់ភេទដូចគ្នា។ គាត់កំណត់ខ្លួនជាស្ត្រី និងមានដៃគូជាអ្នកប្តូរយេនឌ័រជាបុរស ដែលអ្នកទាំងពីរបានចូលរួមជាសមាជិកសហគមន៍ឥន្ទធនូកម្ពុជាចាប់តាំងពីឆ្នាំ២០០៩មកម្ល៉េះ។ សព្វថ្ងៃអ្នកទាំងពីរមានមុខរបរជាអ្នកធ្វើស្រែចំការ និងបិទស្រាសលក់ ហើយមើលថែចៅតូចៗបីនាក់។ គាត់មានចៅម្នាក់ទៀត ដែលកំពុងធ្វើការរកស៊ីនៅខេត្តផ្សេង ដែលឧស្សាហ៍ទូរស័ព្ទ និងមកផ្ទះពេលបុណ្យទានម្តងៗ ធ្វើឱ្យពួកគាត់មានទំនាក់ទំនងល្អ និងភាពជិតស្និទ្ធជាក្រុមគ្រួសារមួយដ៏កក់ក្តៅ។

នៅក្នុងជំនាន់នោះ ចាស់ទុំគិតគូរ និងចង់ផ្សំផ្គុំគូគ្រងឱ្យម៉ែសាមីន មានគ្រួសារតាំងពីវ័យជំទង់។ ម៉ែមានមនុស្សប្រុសចូលដណ្តឹងជាច្រើននាក់ តែពេលនោះគាត់មិនទាន់យល់ថាការស្រឡាញ់ដូចម្តេចនោះទេ ទោះបីជាម្តាយឪពុករបស់គាត់បានទទួលពាក្យពីគេ ក៏ម៉ែបានចរចាសុំម្តាយ និងចាស់ទុំមិនព្រមរៀបការដែរ។ លុះដល់អាយុ១៨ឆ្នាំ គាត់បានមកស្គាល់ប៉ាសែន តាមរយៈទំនាក់ទំនងរវាងមិត្តភក្តិរបស់ម៉ែសាមីន និងបងប្រុសរបស់ប៉ា សែន ហើយក៏ចេះតែឧស្សាហ៍ជួបគ្នា ដោយសារពួកគាត់ទាំងពីរនាក់ដើរទិញ និងលក់កន្ទក់ជាមួយគ្នា។
ពេលនោះប៉ាសែន នៅទុកសក់វែង តែស្លៀកពាក់បែបដូចជាមនុស្សប្រុស។ គាត់ក៏មិនទាន់ជាចាប់អារម្មណ៍ថាស្រឡាញ់ប៉ាសែននៅឡើយដែរ តែពេលនោះក៏បានចាប់ផ្តើមមានចិត្តអាណិតប៉ាសែន។ រហូតដល់នៅជាមួយគ្នាយូរៗ ទើបបង្កើតជាមនោសញ្ចេតនាឱ្យគ្នាទៅវិញទៅមក ហើយប៉ាសែនបានប្រាប់ពីចិត្ត ដែលប៉ងស្រឡាញ់របស់គាត់ទៅកាន់ម៉ែសាមីន។ គាត់ត្រូវចំណាយពេលអស់រយៈពេលជាងបីឆ្នាំ ក្នុងការពន្យល់ក្រុមគ្រួសាររបស់ពួកគាត់ទាំងសងខាង ហើយរកវិធីធ្វើយ៉ាងណា ដើម្បីអាចរស់នៅជាមួយគ្នាបាន។ ពួកគាត់ក៏និយាយព្រមព្រៀងគ្នា

ជាមុនថា ពួកគាត់ត្រូវតែហ៊ានតស៊ូនឹងការមិនទាន់ទទួលយកពីអ្នកដទៃ ទើបសម្រេចចិត្តមករួមរស់ជាមួយគ្នា។ ជីវិតដៃគូនេះ ពិតជាមានការលំបាក ប៉ុន្តែមិនមែនក្នុងការរកស៊ីចិញ្ចឹមជីវិតទេ គឺភាពអាម៉ាស់ដែលអ្នកខ្លះនិយាយឌឺដងប្រមាថ ដែលគាត់មករួមរស់នៅជាមួយមនុស្សស្រីដូចគ្នា។



ម៉ែសាមីន ជាមួយប្តី និងកូនឈរនៅកណ្តាល រូបថតឆ្នាំ២០១៧

ម៉ែសាមីនបានតំណាលថា៖ « *ពេលនោះមិនមានដៃគូ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នាណាបង្ហាញថាពួកគេស្រឡាញ់គ្នាទេ គឺមានតែដៃគូខ្ញុំប៉ុណ្ណោះ ហើយពួកយើងមិនមានអ្នកជួយពិភាក្សាជាមួយឡើយ។ តែទោះជាមានចិត្តខ្មាសគេ ពួកយើងទាំងពីរនាក់ក៏គិតថា វាជាការជំរុញទឹកចិត្តឱ្យខិតខំប្រឹងប្រែងចិញ្ចឹមជីវិតដោយខ្លួនឯងផ្ទាល់ ជៀសពីការពឹងពាក់អ្នកដទៃដែលនាំឱ្យគេកាន់តែមើលងាយយើងបន្ថែមទៀត។ ការខំប្រឹងរបស់ពួកយើងពិតជាទទួលបានផលមែន គឺពួកយើងប្រឹងប្រែងរកស៊ី ធ្វើស្រែចំការមានជីវភាពសមរម្យ មានហូបចុកគ្រប់គ្រាន់។* »

## ការស្គាល់អ្នកផ្សេងទៀតដែលដូចខ្លួនឯង

ម៉ែសាមីនបានស្គាល់អង្គការសហគមន៍ឥន្ទធនូកម្ពុជាតាមរយៈប៉ាសែន។ ហើយបន្ទាប់មកក៏បានជួបជាមួយនឹងប៉ាស៊ីថា និងប៉ាសាញ់ ដែលជាអ្នកចងក្រងអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសហគមន៍រ៉ក់ ដែលបានមកផ្ទះរបស់គាត់ ដើម្បីស្វែងរកអ្នកស្រឡាញ់ភេទដូចគ្នានៅតំបន់នោះ។ ម៉ែសាមីន មិនសូវជាបានចូលរួមសកម្មភាព និងកម្មវិធីរបស់រ៉ក់ ដែលបានប្រារព្ធធ្វើនៅទីក្រុងភ្នំពេញប៉ុន្មានទេ ដោយសារត្រូវមើលថៅ និងធ្វើកិច្ចការផ្ទះ នៅពេលប៉ាសែនបានទៅចូលរួម។ នេះជាកិច្ចការសំខាន់ ដែលម៉ែជួយជ្រោមជ្រែងឱ្យស្វាមីរបស់គាត់បាននាំយករឿងរ៉ាវរបស់ពួកគាត់ទាំងពីរ និងសមាជិកអ្នកស្រឡាញ់ភេទដូចគ្នាផ្សេងទៀត ទៅជជែកពិភាក្សាដែលជាជំហាននៃការដោះស្រាយបញ្ហាផងដែរ។ នៅពេលដែលម៉ែបានទៅចូលរួមប្រជុំនៅទីក្រុងភ្នំពេញម្តងម្កាល គាត់បានជួយរៀបចំការធ្វើដំណើរ ប្រាប់ពីកន្លែងស្នាក់នៅ និងជួយមើលថែទាំសមាជិកដទៃទៀត ក្នុងនាមជាអ្នកមកពីភូមិស្រុកជាមួយគ្នាផង ក៏ដូចជាសមាជិកសហគមន៍តែមួយផង។ ម៉ែបានរំលឹកទៀតថា៖ «*កាលពីចាប់ផ្តើមស្វែងរកអ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត ក្នុងភូមិស្រុកដំបូងៗ ម៉ែ និងប៉ាជិះកង់ទៅជាមួយគ្នា ច្រើនគីឡូដី ហើយពិបាកជួបគេណាស់ ដោយសារអ្នកខ្លះមិនទាន់ទុកចិត្តយើងទាំងពីរនាក់។ ដូចនេះគេក៏មិនហ៊ានប្រាប់យើងពីអត្តសញ្ញាណរបស់គេដែរ។*»

ម៉ែសាមីន កាន់តែស្គាល់អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត ទាំងនៅខេត្តស្វាយរៀង និងបណ្តាខេត្តផ្សេង ដែលធ្វើឱ្យម៉ែកាន់តែមានភាពកក់ក្តៅជាងមុន។ ម៉ែមើលឃើញថា អ្នកស្រុកភូមិ កាត់បន្ថយការនិយាយមិនល្អ និងការរើសអើង ដែលជាស្ថានភាពល្អប្រសើរជាងកាលដែលម៉ែ និងប៉ាស្រឡាញ់គ្នាដំបូងៗ។ នេះក៏ដោយសារតែគេឃើញម៉ែទៅប្រជុំ និងដឹងថាមានអង្គការសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជួយជ្រោមជ្រែង និងលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូរ។ ម៉ែនៅតែបន្តចូលរួមជាមួយការងាររ៉ក់ ទាំងមានក្តីសង្ឃឹម ជាពិសេសនៅពេលឃើញថារាជរដ្ឋាភិបាលមានការគាំទ្រជាងមុន។ ម៉ែក៏យល់យ៉ាងច្បាស់ថា វាត្រូវការពេល និងការពិភាក្សាគ្នាបន្តទៀត មុនឈានទៅដល់គោលដៅ ដែលសហគមន៍ចង់បាននោះគឺច្បាប់អាពាហ៍ពិពាហ៍។ ម៉ែសាមីន ចង់ឱ្យមានច្បាប់រៀបការស្មើភាពគ្នាសម្រាប់អ្នកស្រឡាញ់

ភេទដូចគ្នាជំនាន់ក្រោយ នោះពួកគេអាចចុះសំបុត្រអាពាហ៍ពិពាហ៍ សៀវភៅគ្រួសារ និង សៀវភៅស្នាក់នៅជាមួយគ្នាបានពេញលេញ។



រូបថតម៉ែសាមីន និងស្វាមី ថតជុំគ្នាជាមួយសមាជិកអ្នកស្រឡាញ់ភេទដូចគ្នាក្នុងខេត្តស្វាយរៀង ឆ្នាំ២០១៨

នៅពេលស្តាប់ការរៀបរាប់របស់ម៉ែសាមីនហើយ យើងពិតជាមានការស្ងើចសរសើរ ចំពោះចំណេះដឹងដ៏ទូលំទូលាយ បទពិសោធន៍ជីវិតផ្ទាល់ខ្លួន ដែលពោរពេញដោយភាពក្លាហាន ភាពធន់ និងការជួយជ្រោមជ្រែង ដល់ការងាររបស់ស្វាមី ក៏ដូចជាសមាជិកសហគមន៍ខ្លួនដទៃទៀត។ ការតស៊ូអត់ធ្មត់ និងក្តីសង្ឃឹមរបស់ម៉ែ ចំពោះជ័យជម្នះរួមរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា គឺជាកំណត់ត្រា ដែលរ៉ក់គ្រប់ជំនាន់ចងចាំទុក និងរៀនសូត្របានជាដរាប។




# សំ សែន

ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស រស់នៅស្រុកស្វាយជ្រំ
ខេត្តស្វាយរៀង

អង្គុយក្រោមម្លប់ដូង ខ្យល់ជំនោរខែកត្តិកបក់ត្រសៀកៗ អមជាមួយនឹងសំឡេងសត្វពពេចចាបស្រុក ស្រែកយ៉ាងខ្ញៀវខ្ញារអឺងកង និងសំឡេងភ្លេងការរងំៗចេញពីចុងភូមិ លោក សំ សែន បានរាប់រៀបពីប្រវត្តិរឿងរ៉ាវដំណើរដើមទង ពីខ្សែជីវិតរបស់ខ្លួនប្រាប់ដល់កូនក្មួយក្នុងសហគមន៍រ៉ក់យ៉ាងហូរហៃ ប្រកបដោយភាពរីករាយ និងពេញចិត្តនឹងជីវិតរបស់គាត់។ គាត់ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស ហើយចូលចិត្តឱ្យកូនក្មួយក្នុងសហគមន៍ហៅថា «ប៉ា» ។ សព្វថ្ងៃនេះ ប៉ាសែនមានវ័យ៦០ឆ្នាំ កើតនៅក្នុងឆ្នាំ១៩៦៣ និងធំធាត់លូតលាស់ដឹងក្តីនៅលើទឹកដីស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ រំលឹកដល់វ័យជំទង់របស់ប៉ា កាលនៅអាយុ១៥ឆ្នាំ ដែលស្ថិតនៅក្នុងរបបខ្មែរក្រហម ប៉ាមានដៃជើងមាំមួន និងសក់ខ្លីត្រឹមក គាត់ចាប់ផ្តើមមានអារម្មណ៍ស្រឡាញ់មនុស្សស្រីម្នាក់រស់នៅក្នុងកងកុមារភូមិជាមួយគ្នា តែគាត់មិនហ៊ានប្រាប់គេទេ។ លុះក្រោយពីចប់របបខ្មៅងងឹតនោះ ធ្លាប់មានបុរសគេចូលស្តីដណ្តឹងដែរ ស្របពេលដែលគាត់មានសក់វែង តែគាត់មិនមានអារម្មណ៍ស្នេហាជាមួយមនុស្សប្រុសទេ។



រូបថតប៉ាសែន ឃ្វាលគោនៅក្នុងស្រែក្បែរផ្ទះ ឆ្នាំ២០២៤

ក្នុងចន្លោះឆ្នាំ១៩៧៩ ទៅ ១៩៨២ ប៉ាសែនបានរកស៊ីជួញមាន់ទា និងកន្ទក់អង្ករ។ គាត់បានស្គាល់ស្ត្រី ម្នាក់ឈ្មោះ សាមីន ដែលជាប្រពន្ធរបស់គាត់សព្វថ្ងៃនេះ។  ភាគច្រើនក្មេងៗហៅម៉ែសាមីនថា «ម៉ែ» ឱ្យត្រូវជាគូនឹងប៉ាសែន «ប៉ា» ដែលជាប្តី។ គាត់បានស្គាល់ និងរាប់អានគ្នាជាពួកម៉ាក តាមរយៈការមកលេងផ្ទះអ្នកស្គាល់គ្នាម្នាក់ នៅខាងភូមិកំណើតរបស់ម៉ែសាមីន។ ក្រោយមកអ្នកទាំងពីរក៏មានចិត្តស្រឡាញ់គ្នា។ ប៉ាសែន តែងតែចេញចូលផ្ទះម៉ែសាមីនអស់រយៈពេលមួយឆ្នាំ។ ពេលនោះ ក្រុមគ្រួសារឪពុកម្ដាយបងប្អូនរបស់ប៉ា មិនដែលស្តីថាឱ្យគាត់ទេ ហើយម្ដាយរបស់ប៉ាសែន ថែមទាំងប្រាប់គាត់ថា៖ « *បើឡើងចុះៗអ៊ីចឹង កុំឱ្យពិបាកកូនឡើងទៅនៅផ្ទះខាងសាមីនទៅ។* » ពាក្យនេះបានជំរុញចិត្តប៉ា ឱ្យសម្រេចចិត្តរស់នៅទីនោះជាមួយគ្នាដល់សព្វថ្ងៃនេះ។ ពេលប៉ាសែន មករួមរស់កសាងជាគ្រួសារខាងម៉ែសាមីន មេភូមិបានទទួលស្គាល់ដឹងឮ ហើយឪពុកម្ដាយរបស់ប៉ាសែន ក៏បានចែកគោក្របីសម្រាប់ធ្វើស្រែចំការផងដែរ។



រូបថតប៉ាសែន ជាមួយប្រពន្ធ ឆ្នាំ២០១៧

ប៉ាសែន នៅតែតុបតែងខ្លួនជាស្រ្តីនៅឡើយទេ គឺទុកសក់វែង ហើយបួងសក់ឡើងលើ។ ប៉ាស្រឡាញ់សក់ខ្លី តែមិនហ៊ានកាត់ ដោយសារគាត់ខ្មាស់គេ និងគិតថាមនុស្សមានចរិតដូចគាត់ គឺមានតែម្នាក់ឯង។ លុះរស់នៅជាមួយប្រពន្ធបានមួយឆ្នាំ គាត់ក៏បានសម្រេចចិត្តទៅកាត់សក់ទាំងស្ទាក់ស្ទើរ និងលាក់លៀម។ អ្វីដែលពិបាកបំផុត គឺរឿងដែលមានគេសើចយំ មិនចង់រាប់រកទាំងសាច់ញាតិ និងអ្នកជិតខាង ពេលទៅណាមកណាម្តងៗ គេធ្វើដូចជា « មុខមិនឱ្យក្រោយមិនមើល » ។ អ្នកខ្លះបានហៅប៉ាថា មីង តែគាត់មិនខឹងសម្បាជាមួយគេទេ សំខាន់គាត់ស្គាល់ខ្លួនឯងច្បាស់ និងពេញចិត្តខ្លួនឯង។ ប៉ាបាននិយាយថា៖ « អ្វីដែលធ្វើឱ្យប៉ារឹងមាំបំផុត គឺនៅពេលគេនិយាយថា យកគ្នាស្រីនិងស្រីរកធ្វើការអ្វីកើត រកស៊ីអ្វីនឹងរស់ដូចគេ »។ រៀបរាប់ទាំងក្នុងកែវភ្នែកមុត ហើយថែមទាំងមានទឹកភ្នែករលីងរលោងផង គាត់បានបន្តអំពីការឆ្លើយតប ដោយពន្យល់ទៅគេវិញថា៖ « *ការស្រឡាញ់គ្នា មិនសំដៅទៅលើកិលេសតណ្ហាទេ។ ការស្រឡាញ់គ្នា គឺដោយចិត្តនិងចិត្ត អាចរស់នៅជាមួយគ្នា ដឹងទុក្ខធុរៈគ្នា ដឹងឈឺចាប់ ដឹងក្តៅដឹងត្រជាក់ បាយទឹកព្រឹកល្ងាច និងមើលថែគ្នាទៅវិញទៅមក។* » ហើយគាត់ក៏ទន្ទេញប្រាប់ខ្លួនឯងថា៖ « *ខ្ញុំត្រូវតែតាំងចិត្តរឹងមាំ ខ្ញុំត្រូវតែធ្វើអ្វីឱ្យពិតប្រាកដ។* »

នៅពេលប៉ាបានមកប្រកបរបរចិញ្ចឹមជីវិតទាំងរត់ម៉ូតូ ធ្វើសំណង់ និងធ្វើគ្រែ នៅម្តុំអគារប៊ុលឌីងក្នុងរាជធានីភ្នំពេញ ពេលនោះប៉ាចាប់អារម្មណ៍ថាខ្លួនឆ្លាតដែរ គ្រាន់តែមើលគេបៀកថ្នាំផ្ទះ ខ្លួនក៏អាចធ្វើបាន ដែលអាចបណ្តុះជំនាញសាងសង់ និងក្លាយជាជាងផ្ទះមួយរូបរហូតដល់សព្វថ្ងៃ។

ក្នុងឆ្នាំ២០០៩ ប៉ាសែនបានស្គាល់អ្នកចងក្រងបណ្តាញអ្នកស្រឡាញ់ភេទដូចគ្នា នៃអង្គការសហគមន៍ឥន្ទធនូកម្ពុជា ឈ្មោះ ផេង សាញ់ (ប៉ាសាញ់) តាមរយៈពូម្នាក់នៅភូមិខាងកើត ដែលធ្វើការជាមួយជនជាតិបារាំងនៅភ្នំពេញ។ ពូបានប្រាប់ប៉ាសាញ់ថាគាត់មានអ្នកភូមិជាមួយគ្នាម្នាក់ កាត់សក់ដូចបងឯងអ៊ីចឹងដែរ។ ដោយឃើញពីបំណងចង់ជួប និងស្គាល់របស់ប៉ាសាញ់ ពូក៏បានឱ្យលេខទូរស័ព្ទបងថ្លៃរបស់ប៉ាសែនមកប៉ាសាញ់ ដែលនាំឱ្យអ្នកទាំងពីរទាក់ទងគ្នាបានសម្រេច។ ប៉ាសែន បានរំលឹកបន្ថែមថាកាលនោះគាត់កំពុងធ្វើសំណង់នៅម្តុំទួលទំពូង។ រៀងរាល់ម៉ោងបាយថ្ងៃត្រង់ គាត់តែងតែទទួលទូរស័ព្ទរបស់ប៉ាសាញ់ និងប៉ាស៊ីថាជាញឹកញាប់ ហៅគាត់ទៅចូលរួមកម្មវិធីជាមួយសហគមន៍រ៉ក់។ បន្ទាប់ពីផ្តោះផ្តងបានស្គាល់

អ្នកទាំងពីរ ២ទៅ៣ដង ប៉ាសែនក៏ដាច់ចិត្តទៅចូលរួម។ ពេលនោះ ប៉ាសែនចាំថាបានជួបគ្នាដំបូងគឺនៅកម្មវិធីមួយ ដែលធ្វើនៅហាងកាហ្វេនៅម្តុំផ្សារបឹងកេងកង និងក្រោយមកទៀតគាត់បានចូលរួមកម្មវិធីមួយទៀតនៅម្តុំវត្តភ្នំ។ ប៉ាភ្ញាក់ខ្លួន ដោយសារគាត់មើលឃើញមានគេមានឯង ដែលមានចរិតលក្ខណៈដូចគាត់ជាច្រើននាក់ទៀតដែរ ហើយក៏លាន់មាត់ថា៖ « *បើមួយសាលប្រជុំសុទ្ធតែដូចគ្នាទាំងអស់អ៊ីចឹង ខ្ញុំលែងឯកោហើយ។ ក្រោយមក ពេលរ៉ក់បានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃជាអង្គការច្បាស់លាស់ ហើយមានអាជ្ញាធរភូមិឃុំដឹងឮថាយើងជាមនុស្ស ហើយយើងអាចកសាងគ្រួសារបាន ដែលធ្វើឱ្យខ្ញុំកាន់តែលែងភ័យខ្លាចមិនតែលតោល។ អារម្មណ៍របស់ខ្ញុំ គឺប្រៀបបាននឹងមានក្រុមគ្រួសារសុខដុមមួយ មានផ្ទះសម្បែងមានលំនឹង និងមានបង្អែក។* »



ប៉ាសែន ប្រពន្ធ និងកូន ឆ្នាំ២០១៧

ពេលត្រឡប់មកភូមិស្រុកវិញ ប៉ាបានធ្វើដំណើរស្វែងរក និងចងក្រងអ្នកស្រឡាញ់ភេទដូចគ្នា ដែលមិនទាន់ហ៊ានចេញមុខ ឱ្យគេក្លាហានម្តងបន្តិចៗដូចជារូបគាត់ដែរ។ វាជាកិច្ចការលំបាកដែរ តែគាត់មានគ្នា ពេលខ្លះប្រពន្ធរបស់គាត់ទៅជាមួយ ដើម្បីជួយជាយោបល់ថាត្រូវទៅនិយាយអ្វីខ្លះ ដើម្បីចងក្រងសមាជិកថ្មីនោះ។

ក្នុងវេលាថ្ងៃមួយក្នុងឆ្នាំ២០១៣ មានព្រឹត្តិការណ៍មួយកើតឡើង ដែលគួរឱ្យកត់ត្រាទុក។ ប៉ាសែនទៅផ្សារស្វាយជ្រំ បានជួបមនុស្សម្នាក់ដែលមើលទៅគឺ ដូចគាត់ ដែលជាអ្នកប្តូរយេនឌ័រពីស្រ្តីទៅបុរស។ ប៉ាសែនក៏បានហៅរក ណែនាំឱ្យស្គាល់ សុំស្គាល់ឈ្មោះ និងលេខទូរស័ព្ទ ហើយថែមទាំងបានអញ្ជើញចូលរួមកម្មវិធីជាមួយរ៉ក់នៅភ្នំពេញ។ ប៉ាបានប្រាប់ឱ្យស្គាល់ទីតាំងផ្ទះ និងហៅទៅលេង ដើម្បីឱ្យគាត់មានទំនុកចិត្ត។ លុះក្រោយមកទៀត ប៉ាបានឃើញបងប្រុសម្នាក់នោះជិះមកផ្ទះគាត់ គាត់ក៏សួរនាំថាទៅណាដែរ។ បងម្នាក់នោះក៏បានឆ្លើយតបវិញថា « *ខ្ញុំជូនក្មួយទៅពេទ្យក៏ឆ្លៀតមកលេងផ្ទះបង* »។ ចំណេរក្រោយមកយូរគ្រាន់បើ ដោយស្គាល់គ្នាកាន់តែជិតដិត បងប្រុសនោះក៏បានជិះមករកផ្ទះប៉ាសែនតែម្តង ហើយថែមទាំងហ៊ានសារភាពប្រាប់ប៉ាថាកាលនោះគាត់មិនបានជូនក្មួយទៅពេទ្យនោះទេ គឺគាត់ចង់ស៊ើបផ្ទះរបស់ប៉ាសែនថានៅទីនោះមែន ឬអត់។ ប៉ាសែនរៀបរាប់រឿងនេះទាំងអស់សំណើច។ សព្វថ្ងៃបងម្នាក់នោះ និងប៉ាសែនជាសមាជិកសកម្មក្នុងស្រុកស្វាយជ្រំ ចែកគ្នាជួយចងក្រងសមាជិកថ្មី រក្សាទំនាក់ទំនងជាមួយអ្នកចាស់ និងជួយគ្នាទំនាក់ទំនងជាមួយអាជ្ញាធរនៅឃុំផ្សេងគ្នា ក្នុងស្រុកស្វាយជ្រំ។ បងម្នាក់នោះមានឈ្មោះថា « ស៊ុន ភី » ដែលប្អូនៗនៅសហគមន៍រ៉ក់ហៅគាត់ថា « បងភី »។



សកម្មភាពចុះចងក្រងសមាជិកអ្នក ស្រឡាញ់ភេទដូចគ្នា ឆ្នាំ២០១៦

និយាយដល់ត្រឹមនេះ ប៉ាសែនលើកទឹកពិសារបន្តិច ហើយចោលភ្នែកមើលទៅវាលស្រែ គាត់ក៏នឹកត្រឡប់ទៅក្រោយវិញចាប់តាំងពីឆ្នាំ២០០៩ រហូតមកដល់ឥឡូវ។ ប៉ាសែនសង្កេតមើលឃើញថា កូនៗជំនាន់ក្រោយក្នុងសហគមន៍រ៉ក់ ខិតខំស្វះស្វែង ខ្វល់ខ្វាយ និងជួយយកអាសារគ្នា ដែលលើកឡើងដោយស្នាមញញឹម និងសំណើចយ៉ាងកក្អៀករីករាយក្នុងភាពជាឪពុកមួយរូប។ ប៉ាតាំងចិត្តថា៖ « *បើរ៉ក់ នៅតែបន្តទៅមុខ ប៉ានៅតែបន្តពុះពារ ដើម្បីឱ្យបានសំបុត្រអាពាហ៍ពិពាហ៍សម្រាប់ពួកយើងទាំងអស់គ្នា ទោះមិនមែនសម្រាប់ជំនាន់ប៉ា ក៏សម្រាប់ក្មេងៗជំនាន់ក្រោយអាចទទួលបានដែរ។ ប៉ាដក់ចិត្តខ្លាំងបំផុតចំពោះការស្គាល់រ៉ក់ក្នុងជីវិតរបស់ប៉ា ដែលនាំនូវក្ដីសុខមកទល់សព្វថ្ងៃ។ កុំតែមានសហគមន៍រ៉ក់ ប្រហែលម្ល៉េះប៉ាមិនដឹងថានៅទីណា ហើយក៏មិនបានស្គាល់អ្នកណាដែរ។ នៅពេលដែលគេបង្ហាញការខ្ពើមរអើម ប៉ាហ៊ានតវ៉ាការពារខ្លួន ក្រុមគ្រួសារ និងបងប្អូនសមាជិកសហគមន៍យើង ថែមទាំងមានអាជ្ញាធរគាំទ្រ និងទទួលស្គាល់កាន់តែច្រើនជាងមុនផង ។ ហេតុដូច្នេះហើយ អ្នករើសអើងទាំងនោះក៏លែងសូវហ៊ានដែរ។ សំខាន់យើងមានបងប្អូនសមាជិកសហគមន៍យើងច្រើន ទោះបីទៅថ្ងៃមុខយើងអត់ពីរ៉ក់ទៅ យើងនៅតែមានអនុស្សាវរីយ៍ល្អៗជាច្រើនជាមួយគ្នា។* »

ក្នុងនាមជារៀមច្បង ប៉ាសែនចង់ឃើញ និងផ្ដែផ្ដាំដល់អ្នកជំនាន់ក្រោយថា សូមឱ្យកូនក្មួយដាក់ចិត្តដាក់កាយស្រឡាញ់ និងមើលថែគ្នាទៅវិញទៅមក។ សូមកូនៗប្រឹងប្រែង ត្រូវមានសង្ឃឹម និងខំតស៊ូអត់ធ្មត់ឡើង ដើរទន្ទឹមគ្នាទាំងជំនាន់មុន និងក្រោយ។ គាត់លើកឡើងបន្ថែមថាដរាបណារ៉ក់ នៅបន្តទៅមុខទៀត ហើយប៉ានៅតែមានជីវិតរស់នៅ និងមានកម្លាំង ប៉ានៅតែនៅតស៊ូជាមួយរ៉ក់ជានិច្ច។ ភាពជឿជាក់ ទំនុកចិត្ត និងឆន្ទៈដ៏មោះមុត ក្នុងការបន្តចូលរួមពង្រឹង គាំទ្រ និងតស៊ូមតិយ៉ាងសកម្មរបស់ប៉ាសែនមិនរាថយ ដើម្បីសម្រេចក្ដីស្រមៃ នៃតម្រូវការរបស់អ្នកស្រឡាញ់ភេទដូចគ្នា នៅក្នុងសហគមន៍រ៉ក់ គឺគួរឱ្យស្ញប់ស្ញែងខ្លាំងណាស់។



រូបថតជុំគ្នាជាមួយអាជ្ញាធរមូលដ្ឋាន និងសមាជិកអ្នកស្រឡាញ់ភេទដូចគ្នា ឆ្នាំ២០២១



# សុត យន់

ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស រស់នៅស្រុកបាទី
ខេត្តតាកែវ



រូបថតប៉ាយន់ ឆ្នាំ២០១៥

ក្នុងចំណោមរៀមច្បងដែលចូលរួមជាមួយ អង្គការសហគមន៍ឥន្ទធនូកម្ពុជា ចាប់តាំងពីឆ្នាំ២០០៩មកនោះ យើងក៏មានលោក សុត យន់ ឬគ្រប់គ្នាហៅគាត់ថា ប៉ាយន់ម្នាក់ដែរ ដែលប៉ាកើតឆ្នាំ១៩៥៥ ជាអ្នកស្រុកបាទី ខេត្តតាកែវ។ សព្វថ្ងៃគាត់កំណត់អត្តសញ្ញាណខ្លួនជាបុរសដែលមានភេទកំណើតជាស្ត្រី។ តាំងពីធំដឹងក្តី ប៉ាយន់ គឺចូលចិត្ត និងព្យាយាមស្លៀកខោតាមដែលអាចធ្វើបាន។ ប៉ារំលឹកកាលពីពេលដែលគាត់ទៅសាលារៀនថា៖ « *ខ្ញុំនៅចាំពេលខ្ញុំរៀនថ្នាក់ទី២ក្នុងជំនាន់ទស្សវត្សរ៍៧០ ខ្ញុំបានស្លៀកខោទៅរៀន តែគ្រូមិនព្រម ក៏បានដេញឱ្យមកផ្ទះវិញ។ ចិត្តចង់ និងចូលចិត្តស្លៀកខោ ប៉ុន្តែក៏មិនបានគិតថាខ្លួនជាប្រុសដែរ។ ក្រោយមកទៀត ឪពុករបស់ខ្ញុំចង់ឱ្យខ្ញុំរៀបការ តែខ្ញុំមិនព្រមដោយប្រកែកថា បើខ្ញុំយកប្តីនោះនឹងមិនមានអ្នកឡើងត្នោត ធ្វើស្កររកប្រាក់ចិញ្ចឹមពុកទេ។* »

ក្នុងឆ្នាំ១៩៧៦ នាសម័យកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ដែលជាពេលដ៏លំបាកមួយសម្រាប់គាត់ និងប្រជាជនខ្មែរជាទូទៅ ដែលពេលនោះគាត់បានចាប់ចិត្តស្រឡាញ់មនុស្សស្រីម្នាក់ ដែលពេលនោះហើយទើបដឹងច្បាស់ថាខ្លួនជាបុរស។ ប៉ាងឿងឆ្ងល់ពីខ្លួនឯង តែក៏បានស្គាល់ច្បាស់លើចិត្តខ្លួនឯងជាបុរស ហើយស្រឡាញ់ពេញចិត្តនឹងខ្លួនឯង។ គាត់ក៏បានកាត់សក់ រៀបចំសម្ដីសម្ដៅ និងឥរិយាបថ ដែលគាត់យល់ថាបុរសក្នុងជំនាន់នោះគួរធ្វើ ហើយដោយមានកម្លាំងកាយគ្រប់គ្រាន់ផង គាត់ធ្វើកិច្ចការធ្ងន់ៗបានច្រើន។ គាត់បានឆ្លងកាត់ដំណើរជីវិត និងបទពិសោធន៍លំបាកជាច្រើន មុននឹងបានចាប់ដៃជាមួយអ្នកដែលគាត់ស្រឡាញ់ ទាំងការព្យាយាមឃាត់ឃាំង និងបំបែកពីគ្រួសារ ការប្តឹងផ្តល់ ដែលធ្វើឱ្យអ្នកទាំងពីរត្រូវចាកចេញពីស្រុកកំណើត ទៅរកស៊ីចិញ្ចឹមជីវិត នៅពេលគ្មានគ្រួសារសាច់ញាតិគាំទ្រ។ ការលំបាកទាំងនោះ គឺមានគ្រប់រសជាតិ ទម្រាំគាត់អាចត្រលប់មកភូមិឃុំ ចាត់ចែងរៀបចំផ្ទះ

សម្បែង និងយកឈ្នះចិត្ត ឱ្យគ្រួសារទាំងសងខាងទទួលយកបាន។ នៅទីបំផុត ការតស៊ូនោះ បានទទួលលទ្ធផលដែលគាត់ពេញចិត្តមែន ដោយអ្នកទាំងពីររួមរស់ជាមួយគ្នារហូតដល់សព្វថ្ងៃ ជាក្រុមគ្រួសារធំមួយ ដែលមានកូនៗ និងចៅច្រើននាក់។ ប៉ាយន់ប្រើប្រាស់ជំនាញរកស៊ីរបរចិញ្ចឹមជីវិតជាច្រើនមានដូចជា កូរស្ករត្នោតលក់ ធ្វើស្រែ និងជាអ្នករៀបឈុតល្ខោនបាសាក់ ដែលទទួលខុសត្រូវទាំងឆាក ទាំងផ្ទាំងគំនូរឈុតល្ខោននីមួយៗ ឬហៅថាតាតឡូ។ ក្រៅពីមុខរបរទាំងនេះ ប៉ាក៏ព្យាយាមបំពេញតួនាទីជាឪពុក និងជាជីតា ដោយមើលថែ បង្រៀន ប្រៀនប្រដៅ តម្រង់ទិស និងទុកដាក់កូនចៅឱ្យមានគ្រួសារជាដើម។ បន្ថែមទៅលើតួនាទីនោះ គាត់ក៏ជាអ្នកស្ម័គ្រចិត្តជួយកិច្ចការអាជ្ញាធរ ភូមិឃុំ និងជាជនសកម្មនៃរ៉ក់ផងដែរ។



ប៉ាយន់ ជាមួយកូន កូនប្រសារ និងចៅ ក្នុងកម្មវិធីទឹកក់ក្តៅ ឆ្នាំ២០១៩

ដូចទៅនឹងសមាជិកសកម្ម ដែលចូលរួមជាមួយរ៉ក់ដំបូងៗដែរ ប៉ាយន់ចាប់ផ្តើមចេញពីការចូលរួមចងក្រងសហគមន៍ ដោយស្ម័គ្រចិត្តមិនមានប្រាក់កម្រៃ។ ប៉ាបានស្គាល់បណ្តាញអ្នកស្រឡាញ់ភេទដូចគ្នាដំបូង តាមរយៈការចងក្រងជាមួយអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា។ កាលនោះមានអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ទៀតនៅក្នុងស្រុកនោះ បាននាំអ្នកចងបណ្តាញសហគមន៍ដែលមានលោកណយ ស៊ីថា លោកផេង សាញ់ និងចក់ សោភ័ណ្ឌ

មកជួប និងណែនាំឱ្យស្គាល់គាត់។ ពេលបានជួបប៉ាស៊ីថា គាត់ក៏ដឹងថា ពួកគាត់ធ្លាប់ស្គាល់គ្នាតាំងពីនៅក្មេង ដែលគាត់ធ្លាប់ទៅមើលប៉ាស៊ីថាសម្តែងល្ខោនបាសាក់ តែមិនដែលបាននិយាយ និងរាប់គ្នាស៊ីជម្រៅ។

ប៉ាយន់រៀបរាប់ពីការវិវត្តការងាររ៉ក់ថា កើតចេញពីបាតដៃទទេ ពីមិនមានអ្វីសោះរហូតមានក្រុមច្រើន និងមានថវិកាធ្វើការងារបានច្រើន។ គាត់ចាប់ផ្តើមចងក្រង ពីការចុះជាមួយអ្នកសកម្មម្នាក់ទៀត ដោយជិះកង់ទៅតាមភូមិស្រុក ស្រាវជ្រាវរកអ្នកស្រឡាញ់ភេទដូចគ្នាពីភូមិមួយទៅភូមិមួយ បន្ទាប់មកក៏សុំលេខទូរស័ព្ទ ហើយពេលជួបគ្នាម្តងជាពីរដង ក៏សុំទៅលេងផ្ទះតែម្តង។ ក្រោយមកអ្នកសកម្មម្នាក់នោះបានចំណាកស្រុក ទៅរកការងារធ្វើនៅក្រៅប្រទេស ប៉ាក៏បន្តកិច្ចការទំនាក់ទំនងចងក្រងនេះ និងចូលរួមជាមួយរ៉ក់ អស់រយៈពេល១៤ឆ្នាំកន្លងមកហើយ។



ប៉ាយន់ ជាមួយសមាជិកអ្នកស្រឡាញ់ភេទដូចគ្នា ដែលរស់នៅស្រុកបាទី ខេត្តតាកែវឆ្នាំ២០២០

ប៉ាយល់ថា នេះជាតួនាទីមួយរបស់គាត់ជាអ្នកស្រឡាញ់ភេទដូចគ្នា ហើយជាការងាររួមរបស់អ្នកពាក់ព័ន្ធ ដែលមានឆន្ទៈចូលរួមធ្វើ ហើយប៉ាក៏បានលើកឡើងពីមូលហេតុ ក្នុងការបន្តជាសមាជិកសកម្មថា៖ « *ប៉ាមើលឃើញថាមានមនុស្សជាច្រើន តួយ៉ាងម្ចាស់ជំនួយ គេចូលរួមជួយគិតគូរយើង ទាំងមិនមែនជាបញ្ហាគេសោះ ហើយក្រុមការងាររ៉ក់ ក៏ខិតខំប្រឹងប្រែងចំណាយកម្លាំងកាយ ប្រាជ្ញាគិតគូរហ្មត់ចត់ដែរ។ គ្រប់ពេលឱ្យតែទៅចូលរួមប្រជុំ ប៉ាទុកចិត្តថាមានសុវត្ថិភាពទាំងទីតាំង និងអាហារ។ ដូចនេះយើងត្រូវបំពេញកាតព្វកិច្ចរបស់យើង ជាជនសកម្មដែរ ប្រសិនបើយើងមានបំណងចង់ឱ្យសង្គមទទួលស្គាល់ខ្លួន និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ។* »



កម្រងអនុស្សាវរីយ៍ ថតឆ្នាំ២០២៤ ដែលប៉ាយន់តាំងនៅផ្ទះ

ពីការប្រឹងប្រែងកន្លងមក ប៉ាយន់ពេញចិត្តនឹងលទ្ធផលសព្វថ្ងៃ ហើយក៏មានសង្ឃឹមថា ស្ថានភាពសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា កាន់តែប្រសើរឡើង ជាពិសេស គឺសម្រេចគោលដៅនៃការផ្លាស់ប្តូរស្ថានភាពច្បាប់។ ខាងក្រោម គឺជាពាក្យពេចន៍ដ៏គួរឱ្យរំជួលចិត្តរបស់គាត់ទៅកាន់សហគមន៍រ៉ក់ ជាពិសេសអ្នកជំនាន់ក្រោយ៖ « *តាមការចូលរួមជាមួយរ៉ក់លើកដំបូងៗ ពួកយើងនិយាយរឿងការមិនរើសអើង និងមានសិទ្ធិសេរីភាពធ្វើការងារជាដើម។*

*ហើយពេលបានឃើញសម្ដេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនាពេលនោះ បានគាំទ្រជាសាធារណៈទៀត គឺដូចជាការលើកទង់ជ័យមួយ សម្រាប់សហគមន៍ពួកយើង! យើងខិតខំអស់រយៈពេលច្រើនគួរសមដែរ ហើយកាន់តែខិតជិតដល់ភាពជោគជ័យនៃការមានច្បាប់អាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា! វ័យខ្ញុំកាន់តែជ្រេហើយ ដូចនេះខ្ញុំសង្ឃឹមថា ពេលវេលានោះនឹងឆាប់មកដល់ ដែលខ្ញុំនឹងអាចមើលឃើញផ្ទាល់ភ្នែក ជាពិសេសឃើញអ្នកជំនាន់ក្រោយរៀបការតាមច្បាប់ពេញលេញ ក្នុងនាមជាប្រជាពលរដ្ឋខ្មែរ។ ខ្ញុំសង្ឃឹមថាសមាជិកសហគមន៍ជំនាន់ក្រោយនឹងនៅតែខំប្រឹងបន្តសម្រេចក្ដីស្រម៉ៃនេះ។»*




រូបថតជុំសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកគាំទ្រ ថតក្នុងឱកាសកិច្ចសន្ទនាជាមួយរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៣

ប៉ាយន់ ជាចាស់ទុំមួយរូប ដែលមានឆន្ទៈបំពេញតួនាទីយ៉ាងសកម្ម និងមានទំនួលខុសត្រូវខ្ពស់ ឱ្យតម្លៃលើការធ្វើជាពលរដ្ឋល្អ ជាហេតុនាំឱ្យសមាជិកជំនាន់ក្រោយរួមទាំងអ្នកនៅក្នុងភូមិឃុំគោរពស្រឡាញ់ ហើយអ្នកខ្លះក៏យកគាត់ជាគំរូផងដែរ។ ប៉ា រមែងចែករំលែកចំណេះដឹង និងផ្ដល់ឱកាសឱ្យសមាជិកដទៃ ជាពិសេសអ្នកវ័យក្មេងមកចូលរួម និងនាំទៅស្គាល់សមាជិកទូទៅ ដើម្បីឱ្យគេអាចរៀនសូត្រពីការងារចងក្រងសហគមន៍ ហើយពួកគេក៏អាចធ្វើការងារបន្តពីគាត់បាន។ រីឯអាជ្ញាធរក្នុងភូមិឃុំរបស់គាត់ ក៏ទៅសុំយោបល់ពីគាត់ទាក់ទងនឹងប្រជាពលរដ្ឋ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នានៅទីនោះដែរ។ លទ្ធផលនេះសបញ្ជាក់ឱ្យឃើញពីការទទួលស្គាល់នូវការខិតខំប្រឹងប្រែង យកចិត្តទុកដាក់ខ្វាយខ្វល់ និងសេចក្ដីល្អរបស់ប៉ា ចំពោះសហគមន៍។



# សែម អៀង

ជាស្ត្រីស្រឡាញ់ស្ត្រី រស់នៅស្រុកបាទី ខេត្តតាកែវ


រូបម៉ែអៀម ក្នុងកម្មវិធីសមាជរ៉ក់លើកទី៣ ឆ្នាំ២០២១

ជាស្ត្រីម្នាក់មានឈ្មោះ សែម អៀង ឬម៉ែអៀង កើតនៅឆ្នាំ១៩៥៣ និងជាអ្នកស្រឡាញ់ភេទដូចគ្នា រស់នៅក្នុងស្រុកបាទី ខេត្តតាកែវ។ យើងសូមចាប់ផ្តើមសាច់រឿងរបស់គាត់ ចាប់ពីពេលដែលគាត់កត់សម្គាល់ពីចិត្តខ្លួនឯង មានចំពោះមិត្តភក្តិស្រីម្នាក់ឈ្មោះ សុត យន់ ដែលសព្វថ្ងៃយើងហៅថាប៉ាយន់។ នេះជាការចាប់ផ្តើម នៃក្តីស្រឡាញ់របស់គាត់ ជាមួយមនុស្សស្រីដូចគ្នា និងជាគូស្នេហាមកដល់ពេលបច្ចុប្បន្ននេះ។ ដំបូងពួកគាត់ទាំងពីរគឺជាមិត្តភក្តិ រស់នៅក្នុងភូមិជាមួយគ្នា តាំងពីតូចៗមករហូតដល់ឆ្នាំ១៩៧៦ នៃរបបខ្មែរក្រហម។ ពួកគាត់ទាំងពីរ បាននៅក្នុងកងចល័តមួយជុំគ្នានៅស្រុកមួយទៀត ដែលជាក្រុមមនុស្សពេញវ័យធ្វើការប្រើកម្លាំងដូចជាធ្វើស្រែ និងរែកដីជាដើម។ ដូចពាក្យចាស់លោកពោលថា « *នៅផ្ទះម្តាយទីទៃ នៅព្រៃម្តាយតែមួយ* » អ្នកទាំងពីរមើលថែគ្នា ហើយទំនាក់ទំនងក៏កាន់តែស្និទ្ធស្នាលឡើងៗ។ ប៉ាយន់ បានជួយថែទាំម៉ែអៀង ដោយការជួយលើករបស់ធ្ងន់ៗ និងជួយសម្រាលទម្ងន់ការងាររបស់ម៉ែមួយចំនួន។ ស្ថិតនៅក្នុងវ័យម្ភៃឆ្នាំជាង គាត់ក៏មិនទាន់ដឹងថា ក្តីស្រឡាញ់បែបស្នេហាយ៉ាងណាដែរ។ មានពេលមួយពួកគាត់បានបែកគ្នា ដោយសារគេជម្លៀសប្តូរប៉ាយន់ ចេញពីកងចល័តនោះ។ ទោះឃ្លាតឆ្ងាយតែកាយក្តី ការយកចិត្តទុកដាក់នៅតែមានចំពោះម៉ែអៀង ដោយប៉ាយន់តែងតែផ្ញើរបស់របរតាមគេឱ្យមកម៉ែអៀង មិនដែលខាន។ រីឯម៉ែវិញ ដេកយំនឹកប៉ាជានិច្ច ដូចជាការនឹករលឹកមិត្តម្នាក់ ដែលធ្លាប់តែនៅក្បែរ តែការយកចិត្តទុកដាក់របស់ប៉ា ហាក់ដូចជាលើសពីមិត្តធម្មតា ធ្វើឱ្យម៉ែអៀងឆ្ងល់ជាខ្លាំងចំពោះចេតនារបស់មិត្តខ្លួន និងចិត្តរបស់ខ្លួនឯងចំពោះគេ។ ក្រោយមក ដោយសារមានជំងឺ ធ្វើការឱ្យគេមិនកើតជាញយដង ណាមួយត្រូវបានគេគំរាមសម្លាប់ទៀតនោះ ម៉ែអៀងក៏បានលួចរត់ចេញពីកងចល័តនោះជាមួយពួកម៉ាករបស់គាត់ ទៅស្រុកកំណើតគាត់វិញ។ នៅពេលមកដល់ទីនោះប្រហែលបាន ១០ថ្ងៃ គាត់បានជួបជាមួយប៉ាយន់ម្តងទៀត ហើយពួកគាត់ តែងតែស្កាត់ជួបគ្នាមិនដែលខាន។




ម៉ែអៀម និងប្តី ក្នុងពិធីចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ ក្នុងឆ្នាំ២០២២

ថ្ងៃមួយ នៅពេលដែលម៉ែអៀងទៅធ្វើជាអ្នកកំដរកូនក្រមុំក្នុងពិធីមង្គលការមួយ ដែលគាត់ត្រូវទៅគេងនៅផ្ទះកូនក្រមុំ ដើម្បីក្រោកពីយប់តុបតែងខ្លួន ជាឱកាសល្អ ពេលនោះ ប៉ាយន់បានហៅម៉ែអៀង មកស្នាក់នៅផ្ទះគាត់ ហើយយកឱកាសសារភាពថាគាត់ស្រឡាញ់ម៉ែអៀងដូចមនុស្សប្រុសស្រីគេស្រឡាញ់គ្នាតែម្តងទៅ។ តែម៉ែអៀងបានប្រកែកថាស្រឡាញ់គ្នាយ៉ាងម៉េចបើស្រីដូចគ្នាហ្នឹង។ ប៉ាយន់ព្យាយាមនិយាយ និងបញ្ជាក់ពីក្តីស្រឡាញ់របស់គាត់ ហើយបបួលម៉ែរស់នៅជាមួយគ្នាជាគ្រួសារ តែម៉ែអៀងមិនព្រមទៅនឹងសំណើនោះទេ។ ប៉ាមិនបានបោះបង់ការព្យាយាមរបស់គាត់ឡើយ ដោយនៅតែតាមពន្យល់ ទោះម៉ែនៅស្ទាក់ស្ទើរក៏ដោយ។ អ្នកទាំងពីរនៅតែរាប់អានគ្នា ដើរទៅរកអុស និងស្និទ្ធស្នាលជាធម្មតា។ ម៉ែយល់ថា ទំនាក់ទំនងនេះជាទំនាក់ទំនងមិត្តភក្តិស្និទ្ធស្នាល ដូចបងប្អូនស្រីរាប់អានគ្នា។ តែម៉ែក៏ទន់ចិត្តព្រមទទួលថាចិត្តដែលមានចំពោះប៉ា គឺជាចិត្តស្រឡាញ់លើសពីមិត្តភក្តិស្និទ្ធស្នាលទូទៅ។ ពេលមួយដែលអ្នកទាំងពីរត្រូវបែកគ្នា ដោយម៉ែអៀងត្រូវរៀបការ ប៉ាយន់ក៏ចាកចេញពីស្រុក ធ្វើឱ្យម៉ែនឹករលឹកខ្លាំង បាយមិននឹក ទឹកមិនស្រេក រហូតដល់ធ្លាក់ខ្លួនឈឺ ទៅរកគ្រូខ្មែរ និងពេទ្យមើលតែរកមិនឃើញមូលហេតុជំងឺ ទើបគាត់ដឹងថាគាត់ពិតជារស់នៅដោយគ្មានប៉ាមិនបានទេ។

ការចាប់ផ្ដើមជីវិតដៃគូ របស់គាត់ត្រូវបានឪពុកម្ដាយ និងបងទាំងសងខាងមិនយល់ពីក្ដីស្រឡាញ់ និងទំនាក់ទំនងរវាងស្ត្រីនិងស្ត្រី បូករួមការបារម្ភពីសុខទុក្ខរបស់កូនផង ពួកគាត់បានបំបែកអ្នកទាំងពីរជាច្រើនលើក ច្រើនសារ មានទាំងការប្ដឹងផ្ដល់ទៀតផង។ អ្នកទាំងពីរព្យាយាមរកវិធី ដើម្បីនៅជាមួយគ្នា កសាងជាគ្រួសារ ដោយត្រូវសម្រេចចិត្តចំណាកស្រុកទៅរស់នៅបាត់ដំបងមួយរយៈ តែដោយសារការរកស៊ីនៅទីនោះមិនកាក់កប ក៏ត្រូវស្រុះស្រួលគ្នាត្រឡប់មកស្រុកវិញ។ ចុងក្រោយ ដោយមានការជួយជ្រោមជ្រែងពីបងដែលជាអ្នកភូមិជាមួយ និងរាប់អានគ្នា ដោយផ្ដល់ដីមួយកន្លែង ដើម្បីសង់ខ្ទមស្នាក់នៅ។ ការរស់នៅពិតជាមិនស្រួលឡើយ តែពួកគាត់ខំប្រឹងរកស៊ីដោយបាតដៃទទេ កាប់អុស ជីកទំពាំងយកទៅលក់នៅឯផ្សារ ដើម្បីបានលុយ បានអង្ករ រហូតដល់បានបើកកន្លែងលក់ អីវ៉ាន់ចាប់ហួយតូចល្មម ដែលអាចចិញ្ចឹមជីវិត និងកូនក្មួយជាសមាជិកក្រុមគ្រួសារមួយរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ក្រោយពីបានតស៊ូជម្នះរាល់ឧបសគ្គ និងការលំបាកជាមួយគ្នាគ្រប់បែបយ៉ាង ម៉ែអៀង និងប៉ាយន់ បានរស់នៅជាមួយគ្នាដោយបើកចំហ មានក្ដីសុខ និងលែងមានអ្នកណាមកបំបែកគាត់ទៀត។

គាត់ធ្លាប់តែគិតថា ការស្រឡាញ់ភេទដូចគ្នាក្នុងជំនាន់នោះ គឺមានតែគ្រួសារគាត់តែប៉ុណ្ណោះ។ ប៉ុន្មានឆ្នាំក្រោយមក គាត់បានជួបអ្នកភូមិម្នាក់ដែលមានអត្តសញ្ញាណជាស្ត្រីតាំងខ្លួនជាបុរស និងមានដៃគូជាស្ត្រី ដែលមកសង្កេតមើលប៉ា និងម៉ែ និងមកដល់ផ្ទះគាត់។ បងម្នាក់នោះបានបបួល និងពន្យល់ម៉ែអៀង និងប៉ាយន់ ឱ្យចូលរួមជាសហគមន៍ ហើយបានហៅពួកគាត់ឱ្យទៅចូលរួមកម្មវិធីរបស់សហគមន៍ម្ដងជាពីរដង តែគាត់មិនបានចាប់អារម្មណ៍ និងជឿទុកចិត្តទេ។ ក្រោយមកក៏មានបុគ្គលពីរបីនាក់ទៀត ដែលម៉ែចាំឈ្មោះយ៉ាងច្បាស់គឺ លោកចក់ សោភ័ណ្ឌ ណយ ស៊ីថា និងផេង សាញ់ បានមកដល់ផ្ទះរបស់គាត់ និយាយទំនាក់ទំនងពន្យល់ពីការចូលរួមរៀនសូត្រ និងស្គាល់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត ទើបអ្នកទាំងពីរសម្រេចចិត្តសាកល្បងចូលរួម ដែលជាពេលចាប់ផ្ដើមចូលរួមជាមួយសហគមន៍ឥន្ទធនូកម្ពុជា។ ពេលបានចូលរួមកម្មវិធីលើកដំបូង គាត់បានឃើញគេ ឃើញឯងដែលជាអ្នកស្រឡាញ់ភេទដូចគ្នា មកពីខេត្តផ្សេងៗ និងមានទាំងបរទេសទៀតផង។ ម៉ែអៀងមានអារម្មណ៍រំភើប និងមិននឹកស្មាន ថាមានអ្នកស្រឡាញ់ភេទដូចគ្នាច្រើន ដែលធ្វើឱ្យគាត់

លែងឯកាដូចពីមុន។ នេះជាការជំរុញទឹកចិត្ត ឱ្យគាត់ជួយជ្រោមជ្រែង និងរំលែកកិច្ចការ ប៉ាយន់បានខ្លះ ដែលអាចឱ្យប៉ាដើរចងក្រងសមាជិកក្នុងភូមិឃុំមួយចំនួន នៅក្នុងស្រុកបាទី ខេត្តតាកែវនេះ។ បន្ថែមទៀត ប៉ាក៏អាចចូលរួមប្រជុំ និងចូលរួមកម្មវិធីរ៉ក់ ជាប្រចាំមិនដែលខកខាន។ ក្រៅពីនោះ គាត់គិតគូររៀបចំ វេចខ្ចប់បាយម្ហូបឱ្យប្តី និងទុកឱ្យគាត់ចែកជាមួយសមាជិកដែលចូលរួមកម្មវិធីផងដែរ។ អ្នកទាំងពីរ ត្រូវបានសមាជិកសហគមន៍ និងអ្នកស្រុកភូមិ គោរពថា ជាដៃគូជីវិតគំរូ ទោះមានភេទស្រីដូចគ្នាក៏ដោយ។



រូបថតក្នុងពិធីចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារ ឆ្នាំ២០២២

បើគិតទៅពិតជាគួរឱ្យសរសើរម៉ែអៀង ដែលជាស្ត្រីម្នាក់មានប្រវត្តិស្នេហាជាមួយស្ត្រីដូចគ្នា ហ៊ានតស៊ូ ជម្នះនឹងឪពុកម្តាយ និងក្រុមគ្រួសារដែលជាមនុស្សជាទីស្រឡាញ់ និងមជ្ឈដ្ឋានសង្គមដ៏តឹងតែង។ នៅទីបំផុត ការតាំងចិត្តតស៊ូដ៏មោះមុតនេះ បានធ្វើឱ្យម៉ែ និងប៉ាអាចរស់នៅជាមួយគ្នា កសាងគ្រួសារ ក្លាយជាឪពុកម្តាយ និងតាយាយ ជាម្លប់ក្នុងក្រុមគ្រួសាររបស់គាត់។ ទោះបីម៉ែអៀង មិនបានចូលរួមបំពេញការងារ ជាអ្នកចងក្រងសមាជិក

សហគមន៍រ៉ក់ ការជួយជ្រោមជ្រែងរបស់ម៉ែចំពោះប៉ាយន់ជាស្វាមី ទាំងបាយទឹក ម្ហូបអាហារ ការជំរុញទឹកចិត្ត ឱ្យចុះចងក្រងនៅតាមភូមិ និងចូលរួមនៅក្នុងកម្មវិធីរបស់រ៉ក់ ហើយខ្លួនសុខចិត្តនៅរ៉ាប់រង មើលថៃកូនចៅ ផ្ទះសម្បែង និងមុខរបរ។ នេះគឺជាស្មារតីនៃការលះបង់ និងសាមគ្គីភាពពោរពេញ ដោយការគោរពបំផុត។ ការរីកចម្រើនរបស់ប៉ាយន់ ក្នុងការជួយកសាង និងពង្រឹងសហគមន៍រ៉ក់ ក៏មានវត្តមាន និងចំណែករបស់ម៉ែអៀងផងដែរ។



# ផាន់ សារី

ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស រស់នៅស្រុកជើងព្រៃ
ខេត្តកំពង់ចាម

*« ក្នុងលោកនេះ តើមានអ្វីដែលកក់ក្តៅជាងក្តីស្រឡាញ់ទៅ! ជាអ្នកស្រឡាញ់ភេទដូចគ្នា គ្មានចង់បានអ្វីក្រៅពីគ្រួសារយល់ ទទួលស្គាល់ និងទទួលយកអត្តសញ្ញាណខ្លួនយើងឡើយ។ »*

ជាក្មេងស្រីម្នាក់ ដែលមានអត្តចរិតដូចក្មេងប្រុស រប៉ិលរប៉ូច ហើយចូលចិត្តលួចខោ របស់បងប្រុសយកមកស្លៀក ព្រោះតែខ្លាចបងវាយ នាយយើងបានត្រៀមកង់នៅក្រោយផ្ទះ ទុកជិះគេចខ្លួនរួចជាស្រេច។ ដោយហេតុមើលឃើញថានាយចូលចិត្តស្លៀកខោ បងថ្លៃក៏បានកាត់ខោក្រណាត់មួយឱ្យប្អូនស្លៀក ធ្វើឱ្យប្អូនថ្លៃម្នាក់នេះ មានអារម្មណ៍រំភើប និងស្រឡាញ់ខោនោះជាខ្លាំង។



រូបថតប៉ាសារី ក្នុងកម្មវិធីសិទ្ធិមនុស្សឆ្នាំ២០១៤

ផាន់ សារី ជាកូនពៅក្នុងចំណោមបងប្អូនប្រុស-ស្រីសរុប ៦នាក់នៃគ្រួសារ មានជីវភាពសមរម្យមួយ ដែលរស់នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ប៉ុន្តែអ្វីដែលគួរគត់សម្គាល់ គាត់មិនមានអត្តចរិតដូចទៅនឹងអ្វី ដែលផ្តត់គំនិតសង្គមបានគាក់តែងអំពីមនុស្សស្រីនៅជំនាន់នោះឡើយ។ គាត់តែងតែសុំឱ្យម្តាយកាត់សក់ខ្លីឱ្យ ពុំដូច្នោះទេគឺយំក្រាញនៀលដីនៅទីនោះមិនព្រមទៅណា។ គាត់ចូលចិត្តលេងល្បែង ដូចក្មេងប្រុស ជាពិសេស គឺវាយប្រលែងគ្នាជាដើម ហើយថែមទាំងជាក្មេងរប៉ិលរប៉ូចផងនោះ បញ្ហាកើតមាននៅសាលារៀនក៏ច្រើនតាមហ្នឹងផងដែរ។ កាលនៅក្មេង គាត់ខំតស៊ូដើរទៅរៀនផង សុំទៅដោយសារគេផង គួបផ្សំនឹង

បញ្ហាសុខភាពខ្សោយ ឧស្សាហ៍ឈឺច្រើន ទើបធ្វើឱ្យគាត់សម្រេចចិត្តឈប់រៀនទាំងវ័យក្មេង។ កុមារដែលលេងច្រើន រស់រវើក បង្កើតការងារឱ្យឪពុកម្តាយបងប្អូនរវល់ជាមួយច្រើន នាំទាំងការក្តាញ់ ខឹង ស្រឡាញ់ តែកុមារសារីទទួលបានក្តីស្រឡាញ់ពីក្រុមគ្រួសារ គាត់រំលឹកទាំងស្នាមញញឹមថា៖ « *ពុក និងម្តាយខ្ញុំ ស្រឡាញ់ខ្ញុំណាស់ គាត់មិនថាអីទេ ទោះជាខ្ញុំមានសក់ខ្លី និងស្លៀកខោក៏ដោយ* »។

ក្នុងវ័យ១៨ឆ្នាំ យុវជនសារីចាប់ផ្តើមមានទំនាក់ទំនងស្នេហាលើកដំបូងជាមួយមនុស្សស្រីម្នាក់ដែលរស់នៅជិតខាងគ្នា ប៉ុន្តែគាត់ពុំហ៊ានចេញមុខបង្ហាញទំនាក់ទំនងជាចំហឡើយ គឺត្រូវលួចស្ពាត់ជួបគ្នា ដោយលាក់លៀម។ រហូតដល់ឆ្នាំ១៩៨០ គាត់ក៏មានស្នេហាជាលើកទី២ ដែលលើកនេះ គាត់លែងខ្លាចលែងរអែងអ្នកណាហើយ គឺតែងតែពោលប្រាប់អ្នកដទៃក្តែងៗពេញៗមាត់ថា៖ « *នេះជាប្រពន្ធរបស់ខ្ញុំ* » ។ ពួកគាត់រស់នៅ និងប្រកបរបររកស៊ីជាមួយគ្នាធម្មតាដូចគូស្រករ និងប្រជាជនទូទៅដែរ។ កាលជំនាន់នោះ ពុំសូវមានអ្នកស្រឡាញ់ភេទដូចគ្នា ដែលហ៊ានចេញមុខទេ នេះបានន័យថាមានអ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀតដែរ ក្រៅតែពីគាត់ និងដៃគូរបស់ខ្លួន។ មានពាក្យមួយគេលើកថាអ្នកដែលដូចគ្នា គឺច្រើនឆក់រកគ្នា។ ទោះជាអ្នកស្រឡាញ់ភេទដូចគ្នា នៅពេលនោះមិនហ៊ានចេញមុខឱ្យគេឯងដឹងក៏ពិតមែន ក៏យើងអាចមើលគ្នាដឹងដែរ។



រូបថតប៉ាសារី ក្នុងកម្មវិធីសមាជរ៉ក់លើកទី៣ ឆ្នាំ២០២២

ដោយហេតុថាគាត់ជាចាស់ទុំ និងជាសមាជិកចាស់ខែឆ្នាំរបស់សហគមន៍រ៉ក់ ពួកយើងក្មេងៗតែងហៅ និងស្គាល់គាត់ថាប៉ាសារី ដែលមកដល់ឆ្នាំ២០២៣នេះ គាត់មានអាយុ៦៩ឆ្នាំហើយ។ ប៉ាសារីមានមុខរបរចិញ្ចឹមជីវិតផ្សេងៗ ដូចជាការចិញ្ចឹមមាន់ទុកសម្រាប់លក់ ដែលជាមុខរបរជាប់លាប់។ សល់ពេលខ្លះធ្វើនំចំណី ដោយផ្ទាល់ដៃយកទៅលក់នៅឯផ្សារ និងមុខរោងចក្រ ដូចជាកំពិសចៀន នំកង គ្រាប់ល្ពៅលីង រីឯថ្ងៃខ្លះមានកម្លាំងពេញ និងមានចិត្តចង់ផងនោះក៏រៀបចំអង្ករវេចនំអន្សម។ អ្វីដែលយើងស្ងើចសរសើរខ្លាំងនោះ គឺភាពប៉ិនប្រសប់ ពូកែឈ្លាសវៃ និងមានទេព្យកោសល្យពីកំណើតផ្នែកហត្ថកម្ម។ គាត់កាត់ផ្តុំ ឬស្សីធ្វើជាគ្រែ របស់របរប្រើប្រាស់ និងស្នួសម្រាប់ហាលខោអាវជាដើម។ ពោលគឺគ្រាន់តែសង្កេតមើលពីរបៀបដែលជាងធ្វើ គាត់ក៏អាចចេះ និងធ្វើតាមបានយ៉ាងល្អ ហើយស្អាតផងដែរ។ បើភ្ញៀវទៅលេងផ្ទះគាត់ប្រហែលជាមិនចាប់អារម្មណ៍ តែសម្ភារៈមួយចំនួន ដែលគាត់ប្រើប្រាស់ គឺជាស្នាដៃរបស់គាត់ធ្វើផ្ទាល់ ធ្វើចេញពីឬស្សីនៅខាងក្រោយផ្ទះរបស់គាត់។



ប៉ាសារី ជាមួយសមាជិក និងបុគ្គលិករ៉ក់ ទៅសួរសុខទុក្ខអាជ្ញាធរស្រុកជើងព្រៃ ឆ្នាំ២០១៩

ក្នុងឆ្នាំ២០០៩ ប៉ាសារីស្គាល់សហគមន៍ឥន្ទធនូកម្ពុជា តាមរយៈអ្នកចងក្រងសហគមន៍ នៅពេលដែលពួកគាត់ដើរស្វែងរកអ្នកស្រឡាញ់ភេទដូចគ្នាតាមភូមិឃុំ។ គាត់ក៏បានចូលរួម កម្មវិធីជួបជុំសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត នៅឯភ្នំពេញជាបន្តបន្ទាប់ ហើយមានអនុស្សាវរីយ៍ជាច្រើន។ ប៉ារំលឹកពីកម្មវិធី ដែលគាត់បានចូលរួមថា៖ « *ប៉ាចាំបាន និង ពេញចិត្តកម្មវិធីសប្ដាហ៍មោទនភាពឆ្នាំ២០១៨ ដែលធ្វើនៅសួនច្បារមាត់ទន្លេក្រុងតាខ្មៅ។ កាលនោះមានសហគមន៍យើងមកពីច្រើនខេត្ត ហើយនាំគ្នារៀបចំពិធីបណ្ដែតប្រទីប។ ប៉ាបាន កាត់ស្លឹកចេក រៀបដើមចេក តុបតែងប្រទីបមួយព្រឹកធំ!* »។ ប៉ានិយាយបន្តទាំងញញឹមនិង ដោយក្ដីសោមនស្សរីករាយថា៖ « *មកដល់ពេលនេះប៉ាមើលឃើញពីក្ដីសង្ឃឹម៨០% ដែល សហគមន៍យើង អាចទទួលបានច្បាប់អាពាហ៍ពិពាហ៍ ពីព្រោះពួកយើងមានអ្នកគាំទ្រពីក្រសួង ផ្សេងៗ។ ហើយសមាជិករបស់រ៉ក់ កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ប៉ាពេញចិត្តចំពោះភាព រីកចម្រើននេះ។* »



ប៉ាសារី ជាមួយសមាជិក និងបុគ្គលិករ៉ក់ ក្នុងកម្មវិធីជួបជុំសមាជិកឆ្នាំ២០១៧

នៅឆ្នាំ២០១៩ ប៉ាសារី បានខ្នះខ្នែងទំនាក់ទំនង នាំក្រុមការងារសហគមន៍រ៉ក់ ឱ្យស្គាល់ អាជ្ញាធរនៅក្នុងភូមិឃុំរបស់គាត់។ វត្តមានរបស់ប៉ាសារី ដែលជាម្ចាស់ស្រុកទីនេះ មិនបានធ្វើ

ឱ្យអាជ្ញាធរមានភាពភ្ញាក់ផ្អើល ចម្លែក ឬថ្មីស្រឡាងពេកទេ អំពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាឡើយ ដែលហេតុជួយសម្រួលដល់ការងារ ដែលរ៉ក់ធ្វើជាមួយអាជ្ញាធរមូលដ្ឋានផងដែរ។ ពេលនិយាយដល់អាជ្ញាធរ ក៏នឹកដល់ដំណើរខ្ទីឃ្លាតរបស់ប៉ាសារី ទៅធ្វើប័ណ្ណសមធម៌ ដោយជោគជ័យ ដែលគាត់ខំប្រឹងប្រែងទៅជួបស្នើសុំមេភូមិ និងមេឃុំជាដំណាក់ៗ ពន្យល់ប្រាប់ពីជីវភាព និងតម្រូវការជាក់ស្តែង បូកផ្សំ និងការស្តាប់យោបល់របស់ក្រុមការងាររ៉ក់ផង។ គាត់បានសមតាមបំណង ដោយទទួលបាន អត្ថប្រយោជន៍ពីប័ណ្ណសមធម៌ ដែលជាផ្នែកមួយនៃប្រព័ន្ធគាំពារសង្គមដូចជា ការទទួលសេវាពិនិត្យ និងព្យាបាលសុខភាពពីមណ្ឌលសុខភាព ថែមទាំងទទួលប្រាក់ឧបត្ថម្ភប្រចាំខែផងដែរ។ ប៉ាសារីបានចូលរួម ចំណែកឱ្យមានការផ្លាស់ប្តូរបែបវិជ្ជមាន ក្នុងជីវភាពរបស់គាត់ និងអ្នកស្រឡាញ់ភេទដូចគ្នាជាទូទៅ ដោយការរស់នៅបង្ហាញមុខជាសាធារណៈក្នុងភាពជាខ្លួនឯង ការចូលរួមយ៉ាងសកម្មជាមួយសកម្មភាពរ៉ក់ ហើយព្យាយាមជួយទំនាក់ទំនងអាជ្ញាធរហូតមានការយល់ដឹង និងគាំទ្រចំពោះរូបគាត់ផ្ទាល់ ក៏ដូចជាសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត។



ប៉ាសារី ជាមួយសមាជិកសកម្ម និងបុគ្គលិករ៉ក់ឆ្នាំ២០១៩



# សិន នឿន

ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស
រស់នៅស្រុកពារាំង ខេត្តព្រៃវែង

*« ដៃចាប់ទាញមែកឈើតូចមួយ អង្គុយឈ្ងោកឆ្កឹះដី គិតឆ្ងល់ក្នុងចិត្តម្នាក់ឯងថា តើខ្ញុំជាអ្នកណា ហេតុអ្វីបានជាខ្ញុំស្រឡាញ់មនុស្សស្រី បើខ្ញុំជាមនុស្សស្រីដែរហ្នឹង? តើក្នុងលោកនេះ មានតែខ្ញុំម្នាក់ឯងមែនទេ? អាយុ១៣ឆ្នាំ ខ្ញុំបានលួចស្រឡាញ់មនុស្សស្រីម្នាក់ ខ្ញុំសែនឆ្ងល់នឹងខ្លួនឯងណាស់ ជាមិត្តភក្តិនឹងគ្នា តែពេលបាននៅក្បែរគេ ខ្ញុំមានអារម្មណ៍កក់ក្តៅខុសពីមិត្តធម្មតា។ អារម្មណ៍រវើរវាយ ខ្ញុំចង់ស្និទ្ធស្នាលជាមួយគេ ប៉ុន្តែខ្ញុំមិនហ៊ានប្រាប់ និងបញ្ចេញឱ្យគេដឹងទេ ព្រោះខ្លាចពេលដែលនាងដឹងហើយ នាងនឹងឈប់រាប់អានជាមួយខ្ញុំទៀត។ ទំនាក់ទំនងពួកយើងនៅតែជាមិត្តធម្មតា ខ្ញុំតែងតែទៅគេងនៅផ្ទះរបស់នាង ទាល់តែម្តាយរបស់ខ្ញុំហាមឃាត់មិនឱ្យខ្ញុំដើរហើរផ្ទះគេ ចាប់ពីពេលនោះមក ខ្ញុំក៏លែងបានទៅផ្ទះនាងទៀត។ »*



រូបថតបងនឿន នៅឆ្នាំ២០១២

ខាងលើនេះជារឿងរ៉ាវ កាលពីបឋមវ័យខ្លះៗ និងការស្គាល់ខ្លួនឯងរបស់លោកស៊ន នឿន ជាស្ត្រីប្តូរយេនឌ័រទៅជាបុរស មានអាយុ៥៥ឆ្នាំ (កើតឆ្នាំ១៩៦៨) និងមានស្រុកកំណើតនៅស្រុកពារាំង ខេត្តព្រៃវែង។ ក្នុងដំណើរវិវឌ្ឍវ័យរបស់បងនឿន គាត់បានតស៊ូដោះស្រាយការលំបាកក្នុងជីវិតនានា បូករួមទាំងការស្គាល់ និងធ្វើជាខ្លួនឯង។ មកដល់ឆ្នាំ១៩៩៤ ជាពេលវេលាមួយ ដែលបងនឿនមានអារម្មណ៍ឯកោដោយសារស្ថានភាពគ្រួសារប្រែប្រួល ព្រោះសមាជិកក្រុមគ្រួសារបានលាចាកលោក។ ប៉ុន្តែគាត់នៅតែបន្តប្រឹងប្រែងចិញ្ចឹមជីវិត ដោយពឹងលើកម្លាំងញើសឈាមខ្លួនឯង ស៊ីឈ្នួលច្រូតស្រូវ និងទិញស្រូវ ពីអ្នកភូមិរួចដឹកយកទៅលក់បន្តឱ្យឈ្មួញកណ្តាល។ នៅពេលរស់នៅពឹងពាក់ខ្លួនឯងបានបែបនេះ និងមិនមានគំនាបពីគ្រួសារផងនោះ បងនឿន ក៏ចាប់ផ្តើមធ្វើអ្វីដែលខ្លួនស្រឡាញ់ ដូចជាកាត់សក់ខ្លី ហើយស្លៀកពាក់ជាបុរស។ ប៉ុន្តែគាត់នៅតែមានអារម្មណ៍ខ្លាច

រអារក្នុងការរស់នៅចេញមុខនៅក្នុងភូមិស្រុក។ អ្នកស្រឡាញ់ភេទដូចគ្នា ដែលជាស្ត្រីស្រឡាញ់ស្ត្រីនៅក្នុងស្រុកភូមិរបស់បងមានបីទៅបួនគូ ដែលបងនឿនសម្គាល់ឃើញថាគេមិនបង្ហាញអត្តសញ្ញាណខ្លួនទេ តែរស់នៅជាមួយគ្នា និងប្រកបរបរធ្វើស្រែជាធម្មតា។ ក្នុងឆ្នាំ២០០៨ អ្នកភូមិរបស់គាត់ម្នាក់ ដែលជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរសឈ្មោះពៅ បានបបួលគាត់ឱ្យចូលរួមជួបជុំជាមួយអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា ដែលមានសមាជិកសហគមន៍ជាអ្នកប្រកបរបរផ្លូវភេទ និងអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ ពេលនោះគាត់បានស្គាល់លោកណយ ស៊ីថា ឬប៉ាស៊ីថា ដែលជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរសវ័យចំណាស់ម្នាក់ដែរ ហើយក៏បានបង្កើតទំនាក់ទំនងជាមួយអ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនទៀត ជាពិសេសអ្នកដែលមានអត្តសញ្ញាណយេនឌ័រដូចគាត់ ។



បងនឿន ក្នុងកម្មវិធីសមាជរ៉ក់លើកទី៣ ឆ្នាំ២០២២

## សាវតាចូលរួមជាមួយនឹងអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)

ពេលចាប់ផ្តើមកកើតរ៉ក់នៅឆ្នាំ២០០៩ ប៉ាស៊ីថាបានទំនាក់ទំនងបងនឿនមកចូលរួមកម្មវិធីសប្តាហ៍មោទនភាព នៅរាជធានីភ្នំពេញ ក្នុងនាមជាសមាជិកសហគមន៍អ្នកស្រឡាញ់ភេទ

ដូចគ្នាមួយរូប ហើយចូលរួមប្រចាំឆ្នាំជាបន្តបន្ទាប់។ ក្រោយមក គាត់ក៏ត្រូវបានពឹងពាក់ឱ្យជួយទំនាក់ទំនងអ្នកស្រឡាញ់ភេទដូចគ្នាដទៃ ឱ្យស្គាល់គ្នាបានច្រើនជាងមុន ដែលគាត់យល់ថា វាក៏អាចជួយគ្នា ឱ្យជៀសផុតពីភាពឯកា ហើយគាត់ក៏ធ្វើទៅតាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។ ក្រៅពីនោះ បងនឿនក៏បានក្លាយជាសមាជិកសកម្មរបស់រ៉ក់មួយរូប ហើយរមែងបានចូលរួមប្រជុំពង្រឹងសមត្ថភាព ជាមួយសមាជិកសកម្មដទៃទៀត ជាប្រចាំរាល់បីខែម្តង ដើម្បីលើកយកបញ្ហា ដែលជួបប្រទះក្នុងពេលដែលសមាជិករ៉ក់ទូទៅមកពិភាក្សា និងស្វែងរកដំណោះស្រាយ។



រូបថតជុំសហគមន៍ ក្នុងឱកាសប្រជុំសមាជិកសកម្មប្រចាំត្រីមាស ឆ្នាំ២០១៩

ក្នុងឆ្នាំ២០១៧ គាត់ក៏មានឱកាសបង្កើតទំនាក់ទំនងជាមួយអាជ្ញាធរក្នុងឃុំរបស់គាត់ និងឃុំដទៃទៀត តាមរយៈការចុះទៅជួប និងធ្វើសិក្ខាសាលាលើកកម្ពស់ការយល់ដឹងពីគោលគំនិតនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ បងរំលឹកពីការដែលចុះទៅជួបជាមួយអាជ្ញាធរលើកដំបូងថា៖ « *បងចាប់ផ្តើមមានអារម្មណ៍ភិតភ័យជាខ្លាំង ដោយសារមិនធ្លាប់ទៅទាក់ទងអាជ្ញាធរពីមុនមកទេ ដោយគិតថាអាជ្ញាធរមិនបានគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នាឡើយ។ ប៉ុន្តែបងមិនបានបដិសេធ*

*ក្នុងការជូនក្រុមការងាររ៉ក់ទៅទេ។ អំឡុងពេលកំពុងជួបអាជ្ញាធរ បងនៅតែមានអារម្មណ៍ភ័យ និងបុកពោះភឺបៗ។*» ក្រោយពេលជួបជាមួយអាជ្ញាធរបានមួយសន្ទុះ នៅលើផ្ទៃមុខបងនឿនចាប់ផ្ដើមមានស្នាមញញឹម ហាក់បីដូចជារំភើប និងសប្បាយចិត្ត អាជ្ញាធរមិនត្រឹមតែទទួលស្វាគមន៍ពួកយើងដោយរាក់ទាក់ទេ ថែមទាំងណែនាំ និងប្រាប់ព័ត៌មានអំពីអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងភូមិឃុំរបស់គាត់ទៀតផង។ បងនឿនស្ដាប់ដោយក្ដីរំភើប និងញញឹមបិទមាត់មិនជិតឡើយ។ បន្ទាប់ពីនោះមក បងក៏បន្តទាក់ទងជាមួយអាជ្ញាធរមូលដ្ឋានក្នុងឃុំខ្លួន ដោយអារម្មណ៍កក់ក្ដៅ និងមានក្ដីសង្ឃឹម ក្នុងការជួបនឹងអាជ្ញាធរនៅស្រុកផ្សេងផងដែរ។ នៅក្នុងឆ្នាំ២០២០ ដោយសារការចេះបើកចិត្តរៀនសូត្រពីអ្នកដទៃ មិនប្រកាន់វ័យផង បេះដូងចង់ធ្វើការ ដើម្បីជួយដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបន្ថែម ហើយគាប់ជួនដែលបងត្រូវមករកការងារធ្វើនៅភ្នំពេញទៀតផងនោះ បងក៏មានឱកាសធ្វើការជាសមាជិកសកម្មស្ម័គ្រចិត្តពេញម៉ោងនៅរ៉ក់។ បងបានជួយការងារផ្នែកចងក្រង ទំនាក់ទំនង និងលើកទឹកចិត្តសមាជិករ៉ក់នៅតាមខេត្តនានា ជាពិសេសមនុស្សចាស់។ តាមរយៈការងារស្ម័គ្រចិត្តនេះ បងបានចូលរួមចំណែកមួយផ្នែកធំ គឺការរក្សាមិត្តភាព ដោយឧស្សាហ៍ទូរស័ព្ទសួរសុខទុក្ខសមាជិកវ័យចាស់ជាប្រចាំ ដែលធ្វើឱ្យពួកគាត់មានអារម្មណ៍ថាទទួលបានការយកចិត្តទុកដាក់និងភាពកក់ក្ដៅ។



រូបថតបងនឿន ជាមួយបុគ្គលិករ៉ក់ ឆ្នាំ២០២២

បងកាន់តែធ្វើការ បងកាន់តែក្លាហាន ហើយបងក៏កាន់តែយល់ពីស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នា យ៉ាងទូលំទូលាយជាងមុន ទាំងក្នុង និងក្រៅស្រុក តួយ៉ាងអ្នកស្រឡាញ់ភេទដូចគ្នា នៅប្រទេសខ្លះ ត្រូវប្រឈមនឹងស្ថានភាពនៃការរើសអើង ក៏ដូចជាអំពើហិង្សាធ្ងន់ធ្ងរជាងនៅប្រទេសកម្ពុជា រហូតមានការគម្រាមកំហែងដល់អាយុជីវិតទៀតផង តែពួកគេនៅតែតស៊ូពុះពារ។ ភាពក្លាហាន របស់បងនឿនមានការកើនឡើងជាបន្តបន្ទាប់ ហើយជាដំណាក់កាល។ វត្តមានរបស់បងនឿន និងសមាជិកសកម្មដទៃទៀត បានចូលរួមជ្រោមជ្រែង ការងារចងក្រងសហគមន៍របស់រ៉ក់យ៉ាងរឹងមាំ និងរក្សាស្មារតីសាមគ្គីភាព។

នៅពេលជួបជុំជាមួយមិត្តភក្តិ មកពីបណ្តាប្រទេសដទៃ គាត់ទទួលបានការគោរពរាប់អាន ទោះមិនមានភាសាមួយដូចគ្នាក៏ដោយ។ ពេលវេលាមួយនេះ បានធ្វើឱ្យគាត់កាន់តែមើលឃើញពីតម្លៃខ្លួនឯង ដែលធ្វើឱ្យគាត់មានកម្លាំងចិត្តបន្ថែមទៀត។ ពេលត្រលប់មកប្រទេសកំណើតវិញ គាត់ហ៊ាននិយាយអះអាងប្រាប់ទៅសមាជិកសហគមន៍ដទៃ និងអ្នកជិតខាងពីបទពិសោធន៍ ក៏ដូចជាសាច់រឿង ដែលគាត់បានរៀនសូត្រពោរពេញ ដោយទំនុកចិត្ត។ នេះជាដំណើរនៃការផ្លាស់ប្តូរដែលមានអត្ថន័យដ៏ជ្រាលជ្រៅ សម្រាប់បងនឿន ដែលបងអាចទាញសេចក្តីសន្និដ្ឋានបានថារ៉ក់មានតួនាទីសំខាន់ណាស់ ដែលនាំឱ្យបងបានឆ្លងកាត់បទពិសោធន៍ល្អៗ រហូតធ្វើឱ្យបងក្លាយជាមនុស្សម្នាក់ ដែលមានទំនុកចិត្ត និងសេចក្តីក្លាហាន។



ជំនួបអាហារថ្ងៃត្រង់ ជាមួយថ្នាក់ដឹកនាំ អ្នកគាំទ្រ បណ្តាញអង្គការសង្គមស៊ីវិល
និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ឆ្នាំ២០២២

**អនុស្សាវរីយ៍ដែលបងនឹកដល់៖** « *ការចងចាំ និងក្ដីសង្ឃឹមសម្រាប់បងមួយ គឺនៅក្នុងសន្និបាតសមាគមអ្នកស្រឡាញ់ភេទដូចគ្នាប្រចាំអាស៊ី ដែលធ្វើនៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ មានការប្រកាសថា លី ពិសី នឹងមកធ្វើការជាបុគ្គលិកពេញម៉ោងផ្នែក សម្របសម្រួលសហគមន៍រ៉ក់។ បងរំភើប និងសប្បាយចិត្ត ពីព្រោះបងបានស្គាល់គាត់តាំងពីគាត់នៅក្មេង និងតែងចង់ឱ្យគាត់មកធ្វើការជាមួយរ៉ក់ ព្រោះបងមើលឃើញពីឆន្ទៈ ភាពស្មោះត្រង់ មិនវាយឫក និងមើលឃើញពីទេពកោសល្យសម្របសម្រួលរបស់គាត់ល្អ ស្រួលស្ដាប់ ស្ដាប់បាន និងងាយយល់។ ពេលមានបញ្ហា គឺលើកមកដាក់លើតុនិយាយគ្នា មិនអត្តនោម័តិតែម្នាក់ឯង។ ពិសីជាមនុស្សដាក់ខ្លួន មិនបញ្ជា ហើយក៏មិនតាំងខ្លួនជាមេ ពេលយើងចុះធ្វើការតាមខេត្ត ពិសីត្រូវលាងចានគឺលាង មិនប្រកាន់ការងារទេ ហើយជាមនុស្សគិតវែងឆ្ងាយ យកចិត្តទុកដាក់លើសមាជិក ដែលជាមនុស្សចាស់។ ទាំងនេះជាគុណភាព និងគុណតម្លៃនៃភាពជាអ្នកដឹកនាំ របស់សហគមន៍រ៉ក់។* »

បំណងប្រាថ្នារបស់បង ចង់ឱ្យសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ទទួលបានច្បាប់រៀបការ រស់នៅដោយស្មើមុខស្មើមាត់ ដូចទៅនឹងគូស្រករភេទផ្ទុយគ្នា ដោយមិនមានភាពភ័យខ្លាច។ ក្នុងនាមជារៀមច្បងមួយរូប បងបានផ្ដាំទៅសហគមន៍របស់ពួកយើង ជាពិសេសអ្នកជំនាន់ក្រោយថា៖ « *ទោះបីម្នាក់នោះជាអ្នកណា អាយុប៉ុន្មាន ភេទអ្វី ជនជាតិ ឬជាតិសាសន៍អ្វី ត្រូវចេះគោរព ស្រឡាញ់ និងឱ្យតម្លៃគ្នា។ ហើយសូមរក្សាទំនាក់ទំនង យកចិត្តទុកដាក់ចំពោះសមាជិកមានវ័យចំណាស់ផងដែរ* »។

## ផលិតដោយអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) ខែមិថុនា ឆ្នាំ២០២៤

សហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) គឺជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការគាំទ្រសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា។ រ៉ក់ ធ្វើការជិតស្និទជាមួយសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងអាជ្ញាធរមូលដ្ឋានទូទាំងប្រទេសកម្ពុជា ដើម្បីធានាបាននូវការការពាររយៈពេលយូរអង្វែង ព្រមទាំងការគាំទ្រសមភាពសិទ្ធិ និងការទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នា និងគ្រួសាររបស់ពួកគេ។ រ៉ក់មានចក្ខុវិស័យចង់ឃើញប្រទេសកម្ពុជាជាទីកន្លែងដែលប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នា មានអារម្មណ៍រីករាយចំពោះខ្លួនគេ និងរស់នៅប្រកបដោយសុភមង្គល ដោយមានការការពារសិទ្ធិព្រមទាំងទទួលការគោរព និងទទួលស្គាល់ពេញលេញ និងស្មើភាពគ្នាពីគ្រប់ផ្នែកនៃសង្គម ជាពិសេសពីគ្រួសារសហគមន៍ និងអាជ្ញាធរ។


ផ្ទះលេខ៥០D ផ្លូវលេខ៤៥៦ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន
រាជធានីភ្នំពេញ

(+៨៥៥) ១២ ៤៨ ១៥ ៦១/ (+៨៥៥) ៩០ ៨៧៥ ៩២៩

contact@rockcambodia.org


អង្គការសហគមន៍ឥន្ទធនូកម្ពុជា
ROCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

ខ្ញុំទទួលយក